# ខ និងលក្ខខណ្ឌគ្រប់គ្រងប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ិនធើណិតធនាគារកម្ពុជាសាធារណៈ (CPBeBank.com)

## សេចក្តីជូនដំណឹង៖

គេហទំព័រនេះអនុញ្ញាតឱ្យប្រាស្រ័យទាក់ទង និងទំនាក់ទំនងរវាងធនាគារកម្ពុជាសាធារណៈ និងអតិថិជន។ មុនពេលចូលប្រើប្រាស់គេហទំព័រនេះ និង/ឬប្រើប្រាស់ទំព័រទាំងអស់ ឬទំព័រណាមួយ អតិថិជនត្រូវអាន យល់ និងយល់ព្រមអនុវត្តតាមខ និងលក្ខខណ្ឌនានាដែលមាននៅលើគេហទំព័រនេះ ព្រមទាំងខ និងលក្ខខណ្ឌផ្សេងដែលធនាគារអាចកំណត់។ ក្នុងករណីអតិថិជនមិនយល់ស្រុបអនុវត្តតាមខ និងលក្ខខណ្ឌណាមួយ អតិថិជនត្រូវបញ្ឈប់ការចូលប្រើប្រាស់គេហទំព័រ និង/ឬការប្រើប្រាស់ផ្នែកណាមួយនៃគេហទំព័រនេះភ្លាមៗ។

សូមអតិថិជនទាំងអស់មេត្តាជ្រាបថា ការចូលប្រើប្រាស់ ឬការប្រើប្រាស់របស់អតិថិជនលើគេហទំព័រគឺជាការទទួលខុសត្រូវ និងការផ្តួចផ្តើមរបស់អតិថិជន ហើយអតិថិជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

## ១. ទូទៅ

១.១ ព័ត៌មាន ខ្លឹមសារ មាតិកា ឬឧបករណ៍ដែលមាននៅលើគេហទំព័រនេះមិនមែនជាការអញ្ជើញដែលត្រូវចាត់ទុក ឬផ្តល់ជាការចុះកិច្ចសន្យាភ្ជាប់កាតព្វកិច្ចតាមផ្លូវច្បាប់ជាមួយធនាគារកម្ពុជាសាធារណៈ ហើយគេហទំព័រនេះត្រូវបានផ្តល់សម្រាប់តែព័ត៌មានទូទៅប៉ុណ្ណោះ។

១.២ អតិថិជនអាចស្វែងរកការប្រឹក្សាយោបល់ផ្លូវច្បាប់ ហិរញ្ញវត្ថុឯករាជ្យ ឬការប្រឹក្សាយោបល់ផ្សេងៗដែលអតិថិជនយល់ថាចាំបាច់បានគ្រប់ពេល មុនពេលធ្វើការសម្រេចចិត្តណាមួយផ្អែកលើព័ត៌មាន ខ្លឹមសារ ឬមាតិកាណាមួយ។

១.៣ តាមឆន្ទានុសិទ្ធិរបស់ធនាគារកម្ពុជាសាធារណៈ ព័ត៌មាន ខ្លឹមសារ មាតិកា និងមុខងារដែលបានផ្តល់ជូននៅលើគេហទំព័រនេះអាចមានការកែប្រែពីពេលមួយទៅពេលមួយដោយមិនមានការជូនដំណឹង។

១.៤ អតិថិជនរបស់ធនាគារកម្ពុជាសាធារណៈ អាចប្រើប្រាស់សេវានេះបានតែជាមួយគណនីជាប្រាក់ដុល្លារអាមេរិក និងប្រាក់រៀលប៉ុណ្ណោះ។

## ២. និយមន័យ និងការបកស្រាយ

១. "គណនី" សំដៅលើគណនីសន្សំ គណនីចរន្ត ប័ណ្ណឥណទាន គណនីឥណទាន ប្រាក់បញ្ញើមានកាលកំណត់មួយ ឬច្រើន ឬគណនីផ្សេងៗរបស់អតិថិជននៅធនាគារកម្ពុជាសាធារណៈដែលអាចចូលប្រើតាមរយៈសេវាកម្មគេហទំព័រ CPBeBank.com ដែលកំណត់ដោយធនាគារកម្ពុជាសាធារណៈ។

២. "ភ្នាក់ងារ" សំដៅលើភាគីទីបីដែលផ្តល់ផលិតផល សេវាកម្ម មាតិកា និងព័ត៌មានលើគេហទំព័រ។

៣. "កិច្ចព្រមព្រៀង" សំដៅលើកិច្ចព្រមព្រៀងរវាងអតិថិជន និងធនាគារកម្ពុជាសាធារណៈសម្រាប់សេវាកម្មគេហទំព័រ CPBeBank.com រាល់ការបន្ថែម ការធ្វើវិសោធនកម្ម និងការកែប្រែនៅលើគេហទំព័រនេះ។

៤. "បុគ្គលទទួលសិទ្ធិអនុញ្ញាត" សំដៅលើអតិថិជនដែលស្នើសុំប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ។

៥. "ធនាគារ" សំដៅលើធនាគារកម្ពុជាសាធារណៈ ជាក្រុមហ៊ុនដែលបង្កើតនៅព្រះរាជាណាចក្រកម្ពុជា មានការិយាល័យនៅអគារធនាគារកម្ពុ លេខ ២៣ វិថីក្រមួនស (ផ្លូវ ១១៤) សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ ភ្នំពេញ ព្រះរាជាណាចក្រ និងសន្តិជនស្របច្បាប់ និងអ្នកផ្តល់សិទ្ធិរបស់ធនាគារ។

៦. "សេវាកម្មធនាគារ" សំដៅលើផលិតផល និងសេវាកម្មរបស់ធនាគារកម្ពុជាសាធារណៈ និងភ្នាក់ងាររបស់ធនាគារដែលអតិថិជនអាចទំនាក់ទំនងបានតាមគេហទំព័រ។

៧. "វិក្កយបត្រ" សំដៅលើវិក្កយបត្រ បង្កាន់ដៃបង់ប្រាក់ សេចក្តីជូនដំណឹង សេចក្តីជូនដំណឹងអំពីការបន្តទម្រង់បែបបទ និង/ឬការស្នើសុំទូទាត់ដែលបានទទួលតាមរយៈអតិថិជនពីក្រុមហ៊ុនទូទាត់ និងដែលត្រូវទូទាត់ក្នុងក្របខណ្ឌពេលវេលានៅលើវិក្កយបត្រ បង្កាន់ដៃបង់ប្រាក់ សេចក្តីជូនដំណឹង សេចក្តីជូនដំណឹងអំពីការបន្ត ទម្រង់បែបបទ និង/ឬការស្នើសុំទូទាត់។

៨. "ម៉ោងប្រតិបត្តិការ" សំដៅលើម៉ោងរយៈពេល ២៤ ម៉ោង រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក។

៩. "អតិថិជន" សំដៅលើឯកត្តបុគ្គល ឬបុគ្គល ឬក្រុមហ៊ុនដែលមានឈ្មោះគណនីនៅធនាគារកម្ពុជាសាធារណៈ និងបុគ្គលដែលធនាគារកម្ពុជាសាធារណៈ បានព្រមព្រៀងផ្តល់សេវាកម្មគេហទំព័រ CPBeBank.com និងសន្តិជនស្របច្បាប់ ឬអ្នកតំណាងស្របច្បាប់របស់អតិថិជន។

១០. "គណនីដែលអនុញ្ញាត" សំដៅលើ៖

ក. ក្នុងករណីអតិថិជនជាឯកត្តបុគ្គល គណនីឯកត្តបុគ្គលជាឈ្មោះតែមួយ ឬគណនីរួមដែលអតិថិជនបើកគណនីជាមួយបុគ្គលផ្សេង និងក្នុងករណីអាណត្តិធ្វើប្រតិបត្តិការគណនីរួមនោះមាននរណាម្នាក់ក្នុងចំណោមពួកគេចុះហត្ថលេខា ឬ

ខ. ក្នុងករណីអតិថិជនជាក្រុមហ៊ុន គណនីដែលមានតែងតាំងបុគ្គលត្រូវបានអនុញ្ញាតដោយអតិថិជនជាក្រុមហ៊ុនដើម្បីចូលប្រើ និងប្រើប្រាស់សេវាកម្មគេហទំព័រ CPBeBank.com ក្នុងនាម និងជំនួសមុខឱ្យអតិថិជនជាក្រុមហ៊ុន។

១១. "ការបញ្ជា" សំដៅលើការបញ្ជាដែលផ្តល់ដោយអតិថិជនពាក់ព័ន្ធទៅនឹងគណនីរបស់អតិថិជនតាមរយៈសេវាកម្មគេហទំព័រ CPBeBank.com ។

១២. "អ៊ិនធើណិត" សំដៅលើបណ្តាញកុំព្យូទ័រ ដែលតភ្ជាប់អ៊ិនធើណិតតាមរយៈបណ្តាញ TCP/IP ដើម្បីសម្រួលដល់ការបញ្ជូន និងផ្លាស់ប្តូរទិន្នន័យ។

១៣. "អ្នកផ្តល់សេវាកម្មបណ្តាញ" សំដៅលើអ្នកផ្តល់សេវាកម្មបណ្តាញអ៊ិនធើណិត ឬអ្នកផ្តល់សេវាកម្មពាណិជ្ជកម្មតាមអនឡាញ ឬអ្នកផ្តល់សេវាទូរគមនាគមន៍ដែលទទួលបានអាជ្ញាប័ណ្ណដែលទទួលបានការអនុញ្ញាតពីធនាគារក្នុងការតភ្ជាប់បណ្តាញអ៊ិនធើណិត ឬផ្តល់ជូនអតិថិជននូវសេវាទូរគមនាគមន៍ និងការតភ្ជាប់ចាំបាច់នានាដើម្បីផ្តល់ជូនកម្មវិធីណាមួយបន្ថែមទៅនឹងបណ្តាញរបស់ខ្លួន។

១៤. "PAC" សំដៅលើលេខផ្ទៀងផ្ទាត់ CPBe ដែលត្រូវបានប្រើប្រាស់ដើម្បីបញ្ជាក់ និងអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនាគារតាមប្រព័ន្ធអ៊ិនធើណិតដែលធ្វើឱ្យមានប្រសិទ្ធភាពដោយអតិថិជន។ PAC នឹង

បញ្ជូនតាមរយៈប្រព័ន្ធផ្ញើសារខ្លី (SMS) ដោយក្រុមហ៊ុនទូរគមនាគមន៍ទៅកាន់លេខទូរស័ព្ទដៃរបស់អតិថិជនដែលបានកត់ត្រានៅធនាគារ។

១៥. "លេខកូដសម្ងាត់" សំដៅលើតួអក្សរពិសេសចេញដោយធនាគារកម្ពុជាសាធារណៈសម្រាប់ការចូលប្រើគេហទំព័រ CPBeBank.com លើកដំបូងរបស់អតិថិជន ហើយក្រោយមកអតិថិជនតម្រូវឱ្យជ្រើសរើស និងប្ដូរលេខសម្ងាត់ថ្មីដែលត្រូវវាយបញ្ចូលដោយ អតិថិជនដើម្បីផ្ទៀងផ្ទាត់ ភាពត្រឹមត្រូវនៃអត្តសញ្ញាណអ្នកប្រើប្រាស់ និងផ្ដល់អតិថិជននូវសិទ្ធិចូលប្រើប្រាស់គេហទំព័រ CPBeBank.com។

១៦. "ក្រុមហ៊ុនទូទាត់" សំដៅលើក្រុមហ៊ុន ឬអង្គភាពដែលអនុញ្ញាតដោយធនាគារ ហើយឈ្មោះក្រុមហ៊ុននោះត្រូវបានបង្ហាញលើគេហទំព័រ CPBeBank.com ត្រង់អេក្រង់ទូទាត់វិក្កយបត្រ។

១៧. គេហទំព័រ CPBeBank.com សំដៅលើប្រតិបត្តិការធនាគារតាមអ៊ិនធើណិតដែលអតិថិជនអាចចូលប្រើប្រាស់តាមរយៈកុំព្យូទ័រផ្ទាល់ខ្លួន មូដឹម និង/ឬឧបករណ៍ទូរគមនាគមន៍ផ្សេងទៀត តាមអ៊ិនធើណិតបន្ទាប់ពីកែតម្រូវធាតុចូលអត្តសញ្ញាណអ្នកប្រើប្រាស់ និងលេខសម្ងាត់របស់អតិថិជន។

១៨. "CPB" សំដៅលើធនាគារកម្ពុជាសាធារណៈ។

១៩. "ឧបករណ៍" សំដៅលើកុំព្យូទ័រ ឬទូរស័ព្ទដៃដែលអាចប្រើប្រាស់ដើម្បីភ្ជាប់អ៊ិនធើណិត។

២០. "US Dollar" ឬ "USD" សំដៅលើរូបិយប័ណ្ណស្របច្បាប់នៅកម្ពុជាដែលត្រូវប្រើប្រាស់សម្រាប់សេវាគេហទំព័រ CPBeBank.com។

២១. "ខ្មែររៀល" សំដៅលើ រូបិយប័ណ្ណស្របច្បាប់នៅកម្ពុជា ដែលត្រូវប្រើប្រាស់សម្រាប់គេហទំព័រ CPBeBank.com។

២២. "ខ និង លក្ខខណ្ឌ" សំដៅលើខ និងលក្ខខណ្ឌ ដែលគ្រប់គ្រងការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com។

២៣. "អត្តសញ្ញាណអ្នកប្រើប្រាស់" សំដៅលើលេខកូដអត្តសញ្ញាណចូលប្រើប្រាស់ដែលចេញដោយធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ហើយក្រោយមកអតិថិជនតម្រូវឱ្យជ្រើសរើស និងវាយបញ្ចូលសម្រាប់តភ្ជាប់ប្រព័ន្ធគេហទំព័រ CPBeBank.com ជាមួយនឹងអត្តសញ្ញាណអ្នកប្រើប្រាស់ និងគណនីរបស់អ្នកប្រើប្រាស់។

២៤. "គេហទំព័រ" សំដៅលើគេហទំព័រ CPBeBank.com ឬអាសយដ្ឋានផ្សេងទៀត ដែលកំណត់ និងជូនដំណឹងដោយធនាគារពីពេលមួយទៅពេលមួយ។

២.២ ពាក្យពេជន៍ឯកវចនៈរាប់បញ្ចូលទាំងពហុវចនៈ និងផ្ទុយទៅវិញ។

២.៣ ពាក្យពេជន៍បុំលិង្គរាប់បញ្ចូលទាំងឥត្ថីលិង្គ និងអលិង្គ និងផ្ទុយទៅវិញ។

២.៤ វាក្យស័ព្ទធនាគារដែលមិនបានកំណត់និយមន័យ ឬរៀបរាប់ច្បាស់លាស់នៅក្នុងខ និងលក្ខខណ្ឌនេះត្រូវបានបកស្រាយស្របតាមការអនុវត្តទូទៅរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ វាក្យស័ព្ទដែលពាក់ព័ន្ធទៅនឹងបច្ចេកទេសកុំព្យូទ័រដែលមិនបានកំណត់និយមន័យ ឬរៀបរាប់ច្បាស់លាស់នៅ

ក្នុងខ និងលក្ខខណ្ឌនេះត្រូវបានបកស្រាយស្របតាមការអនុវត្តទូទៅ និងឧស្សាហកម្មព័ត៌មានវិទ្យានៅកម្ពុជា។

២.៥ ក្នុងករណីមានការបកស្រាយខ និងលក្ខខណ្ឌខុសគ្នាក្នុងភាសាណាមួយ ភាសអង់គ្លេសត្រូវយកជាគោល។

២.៦ ក្នុងករណីមានបុគ្គល ឬភាគី ២ ឬច្រើនមាននៅក្នុងការបង្ហាញនៃពាក្យថា "អតិថិជន" កិច្ចព្រមព្រៀង កិច្ចសន្យា ការធានាអះអាង ខ និងលក្ខខណ្ឌដែលបានបង្ហាញ និងធ្វើឡើយដោយ និងទៅលើផ្នែកអតិថិជនដូចមាននៅក្នុងខ និងលក្ខខណ្ឌនេះត្រូវចាត់ទុក និងយល់ថាធ្វើឡើង ឬភ្ជាប់កាតព្វកិច្ចលើបុគ្គល ឬភាគីរួមគ្នា។

## ៣. កិច្ចព្រមព្រៀង

៣.១ ខ និងលក្ខខណ្ឌ និងរាល់ការបន្ថែម កែប្រែ និងផ្លាស់ប្តូរជារួមបង្កើតកិច្ចព្រមព្រៀងរវាងអតិថិជន និងធនាគារកម្ពុជាសាធារណៈ ("កិច្ចព្រមព្រៀង") និងប្រើប្រាស់សេវាគេហទំព័រ CPBeBank.com។

៣.២ ខ និងលក្ខខណ្ឌដែលប្រើស្របទៅនឹងខ និងលក្ខខណ្ឌ និងវិធាន និងបទប្បញ្ញត្តិដែលមានវិសាលភាពចំពោះគណនីដែលអតិថិជនអះអាងថា គាត់/នាងបានអាន យល់ និងបានព្រមព្រៀងអនុវត្តតាមដោយឥតលក្ខខណ្ឌ ឬដែនកំណត់តាមរយៈការប្រើប្រាស់គេហទំព័រ ឬទំព័រណាមួយនៃគេហទំព័រនេះ។

៣.៣ ក្នុងករណីមានវិវាទ ឬអសង្គតិភាពរវាងខ និងលក្ខខណ្ឌ រួមទាំងលក្ខខណ្ឌ វិធាន និងបទប្បញ្ញត្តិដែលគ្រប់គ្រងគណនីពាក់ព័ន្ធ កំណែចុងក្រោយត្រូវមានប្រសិទ្ធភាពសម្រាប់ការបកស្រាយ និងការអនុវត្តក្នុងកម្រិតវិសាលភាពនៃវិវាទ ឬអសង្គតិភាព។

៣.៤ បន្ថែមទៅនឹងការរៀបរាប់ខាងលើ ខ និងលក្ខខណ្ឌទាំងនេះដែលប្រតិបត្តិស្របទៅនឹងខ និងលក្ខខណ្ឌ និងវិធាន និងបទប្បញ្ញត្តិនីមួយៗដែលមានវិសាលភាពចំពោះខ និងលក្ខខណ្ឌ PB engage KH។

៣.៥ សិទ្ធិទទួលបានពីកិច្ចព្រមព្រៀងនេះអាចត្រូវផ្ទេរមួយផ្នែក ឬទាំងស្រុងទៅក្រុមហ៊ុនណាមួយដែលពាក់ព័ន្ធនឹងធនាគារកម្ពុជាសាធារណៈ។ សិទ្ធិ ឬកាតព្វកិច្ចរបស់អតិថិជនស្ថិតក្រោមកិច្ចព្រមព្រៀងនេះមិនអាចផ្ទេរទៅអង្គភាព ឬបុគ្គលផ្សេងទៀតឡើយ។

៣.៦ ការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com របស់អតិថិជននៅពេលណាមួយត្រូវបញ្ជាក់មកធនាគារពីការទទួលយក និងកិច្ចព្រមព្រៀងរបស់អតិថិជនក្នុងការអនុវត្តតាមខ និងលក្ខខណ្ឌទាំងនេះ។

៣.៧ ក្នុងករណីមានវិវាទក្នុងការបកស្រាយខ និងលក្ខខណ្ឌនេះ ភាសាអង់គ្លេសត្រូវយកជាគោល។

## ៤. គោលបំណងនៃសេវាគេហទំព័រ CPBeBank.com

៤.១ សេវាគេហទំព័រ CPBeBank.com ត្រូវបានផ្តល់ជូនអតិថិជនសម្រាប់ទុកជាយន្តការដែលអាចឱ្យចូលប្រើប្រាស់សេវាហិរញ្ញវត្ថុផ្តល់ជូនដោយធនាគារកម្ពុជាសាធារណៈ។

៤.២ សេវាហិរញ្ញវត្ថុដែលអាចប្រើប្រាស់តាមរយៈសេវាគេហទំព័រ CPBeBank.com ផ្តល់ជូនដោយធនាគារកម្ពុជាសាធារណៈ អាចរួមមានផលិតផលដែលផ្តល់ជូនដោយបុត្រសម្ព័ន្ធរបស់ធនាគារផងដែរ។ ធនាគារកម្ពុជាសាធារណៈអាចមិនរាប់បញ្ចូលសេវាហិរញ្ញវត្ថុណាមួយ ដែលមានលើសេវាគេហទំព័រ CPBeBank.com តាមឆន្ទានុសិទ្ធិរបស់ខ្លួន។

៤.៣ សេវាគេហទំព័រ CPBeBank.com ដែលអតិថិជនអាចប្រើប្រាស់ គឺផ្អែកលើគោលការណ៍ "មិនមានការផ្លាស់ប្តូរ" និងមិនមានការធានាពាក់ព័ន្ធទៅនឹងសេវាគេហទំព័រ CPBeBank.com ដែលក្នុងនោះរួមមានការធានាពាក់ព័ន្ធស្របនឹងគោលបំណង គុណភាពគួរពេញចិត្ត ឬការអនុលោមតាមការបរិយាយ ហើយរាល់ការធានាដែលពាក់ព័ន្ធទៅនឹងច្បាប់ ឬពន្ធគយមិនរាប់បញ្ចូលឡើយ។

បន្ថែមជាងនេះទៅទៀត អតិថិជនព្រមព្រៀងថា ធនាគារកម្ពុជាសាធារណៈមិនអាចធានាថាសូហ្វែនឹងអាចត្រូវគ្នា ឬអាចប្រើប្រាស់ស្របតាមឧបករណ៍ ហើយអតិថិជនយល់ព្រមថា អតិថិជននឹងមិនឱ្យធនាគារកម្ពុជាសាធារណៈទទួលខុសត្រូវចំពោះភាពមិនស៊ីគ្នា ឬការខាតបង់ ឬការខូចខាតឧបករណ៍ដែលអាចបង្កឡើងដោយសូហ្វែ ឬដំណើរការដំឡើង។

## ៥. ការបដិសេធទទួលខុសត្រូវ

៥.១ ធនាគារកម្ពុជាសាធារណៈនឹងយកចិត្តទុកដាក់ដើម្បីធានាថា ភាពសុក្រឹត្យនៃព័ត៌មាន ខ្លឹមសារ និងមាតិកាដែលបានផ្តល់ជូនដោយផ្ទាល់ និងផ្តាច់មុខដោយធនាគារកម្ពុជាសាធារណៈ។ ក្នុងករណីដដែលនេះ ព័ត៌មាន ខ្លឹមសារ និងមាតិកាដែលបានផ្តល់ជូនដោយធនាគារ និងអ្នកផ្តល់សេវាតតិយភាគីលើគេហទំព័រនេះគឺផ្អែកលើគោលការណ៍ "មិនមានការផ្លាស់ប្តូរ" និងលក្ខណៈទូទៅ និងត្រូវស្របទៅតាមកាតព្វកិច្ចរបស់អតិថិជនក្នុងការចាត់ចំណាត់ការផ្លូវច្បាប់ឯករាជ្យ សេវាហិរញ្ញវត្ថុ ឬការជូនដំណឹងផ្សេងៗតាមការចាំបាច់របស់អតិថិជន។

៥.២ ធនាគារកម្ពុជាសាធារណៈ អភិបាល មន្ត្រី បុគ្គលិក ឬភ្នាក់ងាររបស់ធនាគារបដិសេធទទួលខុសត្រូវចំពោះការបង្ហាញ ឬការធានា ឬការបកស្រាយតុណ្ហី មានដូចជាការធានាឋានៈតួនាទី ការមិនរំលោភបំពានសិទ្ធិជាកម្មសិទ្ធិបញ្ញា សារប្រយោជន៍ សុក្រឹត្យភាព ឬភាពសមស្របសម្រាប់គោលបំណងសេវាកម្ម ឬផលិតផលដែលធ្វើប្រតិបត្តិការតាមរយៈគេហទំព័រនេះ។

៥.៣ ធនាគារកម្ពុជាសាធារណៈ និងភាគីផ្សេងៗដែលពាក់ព័ន្ធទៅនឹងការបង្កើត ការផលិត ឬការផ្តល់សេវានៃគេហទំព័រ CPBeBank.com និងមិនទទួលយកការទទួលខុសត្រូវដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់របស់អតិថិជន។ មិនមានព័ត៌មាន ឬការជូនដំណឹងផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលផ្តល់ជូនដោយធនាគារ ភ្នាក់ងារ ឬនិយោជិតរបស់ធនាគារបង្កើតជាការធានា ឬក្នុងទិដ្ឋភាពណាមួយដែលបង្កើនវិសាលភាពនៃការធានានេះ ហើយអតិថិជនមិនត្រូវពឹងផ្អែកតែទៅលើព័ត៌មាន ឬការជូនដំណឹងនេះឡើយ។

៥.៤ ធនាគារកម្ពុជាសាធារណៈមិនទទួលខុសត្រូវចំពោះការបាត់បង់ណាមួយដែលបានបង្កឡើង ឬការខូចខាតដែលបានកើតឡើង ឬប្រឈមដោយអតិថិជន ឬបុគ្គលផ្សេងៗដោយផលវិបាកនៃការប្រើប្រាស់សេវាដែលបានផ្តល់។

៥.៥ ធនាគារកម្ពុជាសាធារណៈមិនធានា ឬមិនអះអាងថា ការចូលប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃគេហទំព័រនេះ ខ្លឹមសារ មាតិកា ព័ត៌មាន និង/ឬមុខងារនឹងដំណើរការដោយមិនមានភាពរអាក់រអួល ឬគ្មានបញ្ហា ឬភាពខ្វះចន្លោះណាមួយដែលបានកំណត់នឹងត្រូវកែតម្រូវ ឬមិនធានាថានឹងមិនមានការពន្យារពេល ខកខាន បញ្ហា ឬបាត់បង់ព័ត៌មានដែលបានបញ្ជូន ឬការចម្លងមេរោគ ឬខូចទំហំផ្ទុកឯកសារ ឬធានាថាមិនមានការខូចខាតនឹងកើតឡើងមកលើប្រព័ន្ធកុំព្យូទ័ររបស់អតិថិជនឡើយ។

## ៦. ការចូលប្រើ និងការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com

៦.១ ពាក្យស្នើសុំប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ត្រូវស្របតាមគណនីមានសុពលភាពរបស់អតិថិជននៅធនាគារកម្ពុជាសាធារណៈ និងលក្ខណវិនិច្ឆ័យនៃសិទ្ធិទទួលបានដែលមានចែងដោយធនាគារកម្ពុជាសាធារណៈ។

៦.២ ការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com របស់អតិថិជននៅពេលណាមួយ និងពីពេលមួយទៅពេលមួយបញ្ជាក់ពីការយល់ព្រមទទួលយក និងកិច្ចព្រមព្រៀងរបស់អតិថិជនមកធនាគារកម្ពុជាសាធារណៈអំពីបទប្បញ្ញត្តិនៃខ និងលក្ខខណ្ឌ និងហានិភ័យក្នុងការធ្វើប្រតិបត្តិការណាមួយតាមបណ្តាញអ៊ីនធើណិត។

៦.៣ បន្ទាប់ពីការអនុម័តលើពាក្យស្នើសុំរបស់អតិថិជនក្នុងការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com នៅបញ្ជ អតិថិជននឹងទទួលបានអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និងលេខសម្ងាត់។ នៅពេលអតិថិជនចូលប្រើលើកដំបូង អតិថិជនត្រូវប្តូរអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និងលេខកូដសម្ងាត់ថ្មីតាមជម្រើសរបស់គាត់ ឬនាង។

៦.៤ លេខកូដសម្ងាត់ដែលជ្រើសរើសដោយអតិថិជនអាចផ្លាស់ប្តូរនៅពេលណាមួយក៏បានតាមភាពចាំបាច់របស់អតិថិជន។

៦.៥ អតិថិជនមិនត្រូវបង្ហាញលេខកូដសម្ងាត់នេះទៅបុគ្គលណាមួយឡើយ ហើយត្រូវរក្សាភាពប្រុងប្រយ័ត្ន និងការពារកុំឱ្យមានការប្រើប្រាស់ដោយមិនមានការអនុញ្ញាត និងក្លែងបន្លំអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និង/ឬលេខកូដសម្ងាត់ និងគេហទំព័រ CPBeBank.com។

៦.៦ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាមៗអំពីសាខាមានគណនីរបស់គាត់ ឬធនាគារទៅតាមអាសយដ្ឋានដូចមាននៅក្នុងប្រការ ៣១ ខាងក្រោមក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទដៃ និង/ឬអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និង/ឬប្រសិនបើលេខកូដសម្ងាត់ត្រូវបានគេស្គាល់។

៦.៧ ក្នុងករណីម្ចាស់គណនីរួម អាណត្តិធ្វើប្រតិបត្តិការគណនីត្រូវកំណត់ដូចគ្នានៅក្នុងទម្រង់បែបបទស្នើសុំបើកគណនីដែលកំណត់ដោយធនាគារកម្ពុជាសាធារណៈ។ ក្នុងករណី អាណិត្តសម្រាប់ធ្វើប្រតិបត្តិការគណនីអាចឱ្យនរណាម្នាក់ចុះហត្ថលេខាបាន ម្ចាស់គណនីរួមនឹងទទួលបានអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និងលេខកូដសម្ងាត់ដាច់ដោយឡែកសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់ម្ចាស់គណនីរួម។ រាល់ប្រតិបត្តិការលើគណនីនេះត្រូវភ្ជាប់កាតព្វកិច្ចរួមលើម្ចាស់គណនី។

៦.៨ ការចូលប្រើប្រាស់សេវាគេហទំព័រ CPBeBank.com របស់អតិថិជននឹងមានដំណើរការ ហើយរាល់ការបញ្ជា និងប្រតិបត្តិការដែលធ្វើឡើងបន្ទាប់អតិថិជនចូលប្រើប្រាស់ដោយជោគជ័យតាមរយៈអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និងលេខកូដសម្ងាត់ និងការប្រើប្រាស់ PAC/SecureSign Token បើទោះបីជាការចូលប្រើប្រាស់ ការបញ្ជា ឬប្រតិបត្តិការអាចត្រូវបានធ្វើឡើងដោយភាគីទីបីមិនថាទទួលបានការអនុញ្ញាត ឬមិនបានអនុញ្ញាត។

៦.៩ អតិថិជនអះអាង និងធានាបន្ថែមថា រាល់ព័ត៌មាន និងការបញ្ជាទាំងអស់ដែលបានបញ្ជូនមកធនាគារកម្ពុជាសាធារណៈតាមរយៈគេហទំព័រនេះគឺពិតជាត្រឹមត្រូវ មានសុពលភាព និងស្របតាមច្បាប់ដែលភ្ជាប់កាតព្វកិច្ចអតិថិជន។

៦.១០ ធនាគារកម្ពុជាសាធារណៈ និង/ឬអ្នកផ្តល់សេវាជាតតិយភាគីមានសិទ្ធិបញ្ជា ឬប្រតិបត្តិការ និង/ឬពឹងផ្អែកលើការបញ្ជា ឬព័ត៌មានណាមួយដែលបានផ្តល់ពាក់ព័ន្ធទៅនឹងអត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និងលេខកូដសម្ងាត់ និងការប្រើប្រាស់ PAC/SecureSign Token បើទោះបីជា អតិថិជនបានធ្វើប្រតិបត្តិការ និង/ឬបានផ្តល់ព័ត៌មានក៏ដោយ ធនាគារកម្ពុជាសាធារណៈមិនទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតដែលកើតឡើងចំពោះអតិថិជន និង/ឬភាគីទីបី។

៦.១១ អតិថិជនត្រូវបានជូនដំណឹងឱ្យចូលប្រើប្រាស់គេហទំព័រ CPBeBank.com តាមភាពជាក់ស្តែង និងជាប្រចាំដើម្បីធានាថាសមតុល្យគណនី និងប្រតិបត្តិការត្រូវបានធ្វើឡើងត្រឹមត្រូវ។ រាល់ភាពមិនប្រក្រតី ឬអសង្គតិភាពក្នុងសមតុល្យគណនី ឬប្រវត្តិប្រតិបត្តិការត្រូវជូនដំណឹងមកធនាគារកម្ពុជាសាធារណៈជាបន្ទាន់។

៦.១២ អតិថិជនយល់ព្រមថា ការបញ្ជា ឬប្រតិបត្តិការដែលធនាគារកម្ពុជាសាធារណៈបានទទួលមិនអាចកែប្រែបានឡើយ បន្ទាប់ពីធនាគារកម្ពុជាសាធារណៈបានទទួល ឬបានឆ្លើយតប។ ការបញ្ជាដែលធនាគារបានទទួលក្នុងម៉ោងធ្វើការត្រូវមានប្រសិទ្ធភាពនៅថ្ងៃដដែល ដោយហេតុថា ការបញ្ជានេះស្របតាមម៉ោងប្រតិបត្តិការធនាគារ ឬកាលបរិច្ឆេទផ្សេង និង/ឬម៉ោងណាមួយដែលធនាគារកម្ពុជាសាធារណៈកំណត់ពាក់ព័ន្ធទៅនឹងការអនុវត្តជាទូទៅរបស់ធនាគារិក។

៦.១៣ ធនាគារកម្ពុជាសាធារណៈបដិសេធមិនអនុវត្តតាមការបញ្ជា ឬប្រតិបត្តិការណាមួយរបស់អតិថិជនក្នុងករណីការបញ្ជា ឬប្រតិបត្តិការនោះមិនអនុលោមតាមគោលនយោបាយរបស់ធនាគារកម្ពុជាសាធារណៈ ឬច្បាប់ ឬវិធាន ឬបទប្បញ្ញត្តិណាមួយដែលធនាគារកម្ពុជាសាធារណៈត្រូវអនុវត្តតាម ឬដោយសារហេតុផលណាមួយផ្សេងទៀត។

៦.១៤ អតិថិជនទទួលស្គាល់ថាសេវាគេហទំព័រ CPBeBank.com គឺពឹងផ្អែកទៅលើការតភ្ជាប់ និងសេវាកម្មដែលផ្តល់ជូនដោយអ្នកផ្តល់សេវាបណ្តាញ និងអន្តរការីដែលធនាគារកម្ពុជាសាធារណៈបានជួល។ ធនាគារកម្ពុជាសាធារណៈមិនទទួលខុសត្រូវចំពោះការមិនបានបញ្ជូន ឬពន្យារការបញ្ជូនសញ្ញាព្រមាន បញ្ហា ការបាត់បង់ ឬការធ្វើឱ្យខុសពីភាពដើមក្នុងការបញ្ជូនព័ត៌មាន និងការបញ្ជាទៅ/ពីអតិថិជន។

៦.១៥ អតិថិជនទទួលស្គាល់បន្ថែមទៀតថា គាត់/នាងមិនត្រូវប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ក្នុងស្ថានភាពមួយដែលធ្វើឱ្យប៉ះពាល់ដល់លក្ខណពិសេសនៃសុវត្ថិភាព មុខងារសេវា e-Banking ឬព័ត៌មានសម្ងាត់របស់អតិថិជន។

៦.១៦ ដូចបានរៀបរាប់ខាងលើ ធនាគារកម្ពុជាសាធារណៈទទួលបានសិទ្ធិអនុញ្ញាតឱ្យអនុវត្តតាមការបញ្ជាដែលធនាគារបានទទួលតាមសេវាគេហទំព័រ CPBeBank.com។

## ៧. សេវាកម្មដែលអាចប្រើប្រាស់បាន

៧.១ សេវាគេហទំព័រ CPBeBank.com អាចប្រើប្រាស់បានពេញ ២៤ ម៉ោងក្នុងមួយថ្ងៃ រាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក។ ប៉ុន្តែ អតិថិជនទទួលស្គាល់ថា រាល់សេវាគេហទំព័រ CPBeBank.com មិនអាចចូលប្រើប្រាស់បាននៅពេលវេលាណាមួយដោយសារការជួសជុលប្រព័ន្ធ ឬហេតុផលផ្សេងទៀត ឬបុព្វហេតុផ្សេងទៀតដែលលើសពីការគ្រប់គ្រងរបស់ធនាគារកម្ពុជាសាធារណៈ។ អតិថិជនទទួលស្គាល់ថា ធនាគារកម្ពុជាសាធារណៈមិនធានាថា សេវាគេហទំព័រ CPBeBank.com នឹងអាចប្រើប្រាស់បានដោយមិនមានភាពរអាក់រអួលឡើយ។

៧.២ ក្នុងករណីសេវាណាមួយ ឬទាំងអស់នៃគេហទំព័រ CPBeBank.com មិនអាចប្រើប្រាស់បានដោយសារហេតុផលណាមួយ អតិថិជនយល់ព្រមប្រើមធ្យោបាយជំនួស មានដូចជា ម៉ាស៊ីនអេធីអឹម ឬសាខាណាមួយរបស់ធនាគារកម្ពុជាសាធារណៈ ដើម្បីបញ្ជាតាមគោលបំណងរបស់អតិថិជននៅពេលចាំបាច់ណាមួយ។

## ៨. មូលនិធិដែលអាចប្រើប្រាស់បាន

៨.១ អតិថិជនយល់ព្រម និងទទួលស្គាល់ថា ធនាគារកម្ពុជាសាធារណៈមានសិទ្ធិកំណត់កម្រិត និងដាក់លក្ខខណ្ឌលើប្រតិបត្តិការដែលបានធ្វើឡើងដោយអតិថិជន តាមរយៈសេវាគេហទំព័រ CPBeBank.com ក្នុងករណីធនាគារកម្ពុជាសាធារណៈចាត់ទុកថាសមស្របពីពេលមួយទៅពេលមួយ។ អតិថិជនព្រមព្រៀង និងទទួលស្គាល់បន្ថែមទៀតថាប្រតិបត្តិការរបស់អតិជិន បូករួមទាំងការផ្ទេរប្រាក់ (លើកលែងតែប្រការ ១០ ខាងក្រោម) ត្រូវបានកំណត់ក្នុងកម្រិតអប្បរមាប្រចាំថ្ងៃដែលអាចកំណត់ដោយធនាគារកម្ពុជាសាធារណៈ។ អតិថិជនត្រូវធានាថា គោរពតាមកម្រិតនេះ។

៨.២ ស្របតាមសិទ្ធិរបស់ធនាគារកម្ពុជាសាធារណៈក្នុងការកាត់កង ធនាគារកម្ពុជាសាធារណៈមិនចាំបាច់អនុវត្ត ឬធ្វើឱ្យមានប្រសិទ្ធភាពចំពោះការបញ្ជាដែលបានផ្ដល់ ឬប្រតិបត្តិការដែលបានធ្វើឡើងដោយអតិថិជន លុះត្រាតែ និងរហូតទាល់តែគណនីរបស់អតិថិជនមានទឹកប្រាក់គ្រាប់គ្រាន់។ រាល់សិទ្ធិកាត់កងរបស់ធនាគារដែលបានរក្សា ធនាគារអាចអនុវត្ត ហើយប្រតិបត្តិការដែលបានធ្វើ និង/ឬការបញ្ជាដែលបានផ្ដល់ដោយអតិថិជនអាចត្រូវបានធ្វើតាមការបញ្ជាក្នុងករណីធនាគារយល់ថាត្រឹមត្រូវ។

៨.៣ ក្នុងករណីគណនីរបស់អតិថិជនមានការដកប្រាក់លើសកម្រិតកំណត់ ដោយសារហេតុផលណាមួយ ក្នុងនោះរួមមានការអនុវត្តសិទ្ធិកាត់កងរបស់ធនាគារកម្ពុជាសាធារណៈ ឬដោយសារការអនុវត្តតាមការបញ្ជារបស់អតិថិជនដោយធនាគារកម្ពុជាសាធារណៈ អតិថិជនត្រូវទូទាត់ជូនធនាគារតាមការទាមទារនូវចំនួនទឹកប្រាក់ដែលបានដកលើស រួមជាមួយអត្រាការប្រាក់/ប្រាក់ចំណេញទៅតាមអត្រាការប្រាក់/ប្រាក់ចំណេញដែលកំណត់ដោយធនាគារ រហូតដល់ទូទាត់ដាច់ស្រេច បើមិនដូច្នោះ អតិថិជននឹងមិនអនុញ្ញាតឱ្យធ្វើប្រតិបត្តិការណាមួយផ្សេងទៀតក្នុងគណនីរបស់ខ្លួនតាមរយៈសេវាគេហទំព័រ CPBeBank.com ឬតាមបណ្ដាញណាមួយផ្សេងទៀតឡើយ។

៨.៤ ធនាគារកម្ពុជាសាធារណៈមិនធានា ឬអះអាងថា ព័ត៌មានដែលក្នុងនោះរួមមានព័ត៌មានលម្អិតអំពីគណនីអតិថិជនដែលផ្ដល់តាមរយៈសេវាគេហទំព័រ CPBeBank.com គឺពិតប្រាកដ និងត្រឹមត្រូវ ឬជាភស្ដុតាងដាច់ស្រេចដែលបញ្ជាក់ពីគណនីនេះទេ។ អតិថិជនស្វែងយល់ និងយល់ព្រមថា ព័ត៌មានលម្អិតអំពីគណនីដែលបានផ្ដល់ជូនខាងលើអាចមិនមែនជាព័ត៌មានបច្ចុប្បន្ន ឬធ្វើបច្ចុប្បន្នកម្ម ដោយសារអាចមានប្រតិបត្តិការដែលបានធ្វើឡើង និង/ឬការបញ្ជាដែលបានផ្ដល់ដោយអតិថិជនដែលរង់ចាំដំណើរការដោយធនាគារកម្ពុជាសាធារណៈនៅពេលចាំបាច់។

៨.៥ របាយការណ៍គណនីដែលមានបញ្ជាក់ត្រឹមត្រូវដោយមន្ត្រីទទួលសិទ្ធិអនុញ្ញាតរបស់ធនាគារកម្ពុជាសាធារណៈត្រូវចាត់ទុកជាស្ថាពរ និងដាច់ស្រេច និងត្រូវភ្ជាប់កាតព្វកិច្ចចំពោះអតិថិជនជាភស្ដុតាងលើប្រតិបត្តិការទាំងអស់ដែលធ្វើតាមការបញ្ជារបស់អតិថិជន។

## ៩. ការទូទាត់ (រួមមានការទូទាត់វិក្កយបត្រ ឥណទាន ប័ណ្ណ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ)

៩.១ ធនាគារកម្ពុជាសាធារណៈអាចដកក្រុមហ៊ុនទូទាត់ពីបញ្ជីឈ្មោះក្រុមហ៊ុនទូទាត់នៅពេលណាមួយ អតិថិជនព្រមព្រៀងថា ធនាគារកម្ពុជាសាធារណៈនឹងមិនទទួលខុសត្រូវចំពោះការខាតបង់ ឬខូចខាតដែលអតិថិជនអាចទទួលរងដោយសារចំណាត់ការរបស់ធនាគារកម្ពុជាសាធារណៈ។

៩.២ អតិថិជនត្រូវប្រកាន់ខ្ជាប់តាមខ និងលក្ខខណ្ឌរបស់ក្រុមហ៊ុនទូទាត់ពាក់ព័ន្ធទៅនឹងការទូទាត់វិក្កយបត្រ។

៩.៣ អតិថិជនត្រូវអនុញ្ញាតឱ្យក្រុមហ៊ុនទូទាត់ទូទាត់វិក្កយបត្រយ៉ាងតិចបី (៣) ថ្ងៃ។

៩.៤ អតិថិជនយល់ព្រមថា ធនាគារកម្ពុជាសាធារណៈនឹងមិនទទួលខុសត្រូវចំពោះការខាតបង់ ឬខូចខាតដែលកើតឡើង ក្នុងករណីធនាគារកម្ពុជាសាធារណៈមិនអាចធ្វើឱ្យមានប្រសិទ្ធភាពដល់ការទូទាត់ ឬធ្វើឱ្យការទូទាត់មានប្រសិទ្ធភាពទាន់ពេលទៅក្រុមហ៊ុនទូទាត់។

៩.៥ អតិថិជនយល់ព្រម និងទទួលស្គាល់ថា កម្រិតសម្រាប់ការទូទាត់វិក្កយបត្រនេះមានកម្រិតកំណត់ដូចមានចែងនៅក្នុងប្រការ ៨ ខាងលើ។

៩.៦ អតិថិជនទទួលស្គាល់ និងព្រមព្រៀងថា ក្នុងករណីសេវាគេហទំព័រ CPBeBank.com ត្រូវបានប្រើដើម្បីធ្វើឱ្យមានប្រសិទ្ធភាពដល់ទូទាត់វិក្កយបត្រដល់ក្រុមហ៊ុនទូទាត់ ព័ត៌មានដែលបានផ្តល់ដោយអតិថិជនដើម្បីធ្វើឱ្យការទូទាត់មានប្រសិទ្ធភាពនឹងត្រូវបានផ្តល់ទៅក្រុមហ៊ុនទូទាត់ ដើម្បីធ្វើឱ្យការទូទាត់របស់អតិថិជនមានប្រសិទ្ធភាព។ ការព្រមព្រៀងរបស់អតិថិជនឱ្យផ្តល់ព័ត៌មានទៅក្រុមហ៊ុនទូទាត់នឹងត្រូវបានរក្សាទុក និងនៅតែមានសុពលភាពរហូតដល់អតិថិជនលុបចោល។

៩.៧ អតិថិជនទទួលស្គាល់ថា អតិថិជនអាចលុបចោលការព្រមព្រៀងដូចបានរៀបរាប់ខាងលើនៅពេលណាមួយបាន។ ក្នុងករណី អតិថិជនលុបចោលការព្រមព្រៀងរបស់ខ្លួនចំពោះការផ្តល់ព័ត៌មានទៅក្រុមហ៊ុនទូទាត់ដូចបានរៀបរាប់ខាងលើ អតិថិជនយល់ព្រមថា ធនាគារនឹងលែងអាចធ្វើឱ្យការទូទាត់របស់ខ្លួនលែងមានប្រសិទ្ធភាពចំពោះក្រុមហ៊ុនទូទាត់ ហើយអតិថិជនធានាអះអាងថានឹងរៀបចំជម្រើសផ្សេងដើម្បីធ្វើឱ្យការទូទាត់មានប្រសិទ្ធភាពទៅក្រុមហ៊ុនទូទាត់ ក្នុងករណីចាំបាច់។ អតិថិជនយល់ព្រមថា ខ្លួននឹងមិនឱ្យធនាគារទទួលខុសត្រូវចំពោះការអនុវត្តតាមការបញ្ជារបស់អតិថិជនដែលលុបចោលការព្រមព្រៀងរបស់ខ្លួនដូចបានរៀបរាប់ខាងលើ។

## ១០. ការផ្ទេរប្រាក់ (រួមមានការផ្ទេរទៅគណនីធនាគារកម្ពុជាសាធារណៈ ឬផ្ទេរទៅធនាគារផ្សេង)

១០.១ ប្រតិបត្តិការផ្ទេរប្រាក់នៅទីកន្លែង ដែលអតិថិជនកំពុងផ្ទេររវាងគណនីផ្ទាល់ខ្លួនរបស់អតិថិជននៅធនាគារកម្ពុជាសាធារណៈ ការផ្ទេរនេះត្រូវស្របទៅកម្រិតអប្បរមាប្រចាំថ្ងៃដូចមាននៅក្នុងប្រការ ៨ ខាងលើ។

១០.២ ការបញ្ជាផ្ទេរប្រាក់នៅទីកន្លែងដែលអតិថិជនកំពុងផ្ទេរប្រាក់ទៅគណនីភាគីទីបី ដែលមាននៅធនាគារកម្ពុជាសាធារណៈ ឬគណនីណាមួយនៅធនាគារផ្សេង ការផ្ទេរនេះត្រូវស្របទៅកម្រិតអប្បរមាប្រចាំថ្ងៃ និងលក្ខខណ្ឌដែលត្រូវបានកំណត់ និង/ឬការកែប្រែដោយក្រុមហ៊ុនទូទាត់នៅធនាគារកម្ពុជាសាធារណៈ ឬអាជ្ញាធរពាក់ព័ន្ធ។

១០.៣ ក្នុងករណីអតិថិជនផ្ទេរប្រាក់ទៅគណនីភាគីទីបី ("អ្នកទទួល") ដូចមាននៅក្នុងប្រការ ១០.២ ខាងលើ អតិថិជនសូមបញ្ជាក់ជូនធនាគារថា អតិថិជនបានទទួលការយល់ព្រមរបស់អ្នកទទួល និងការអនុញ្ញាតឱ្យផ្តល់ធនាគារនូវលេខទូរស័ព្ទដៃ និង/ឬអាសយដ្ឋានអ៊ីម៉ែលរបស់អ្នកទទួល ដែលធនាគារនឹងប្រើលេខទូរស័ព្ទដៃ និង/ឬអាសយដ្ឋានអ៊ីម៉ែលតាមការបញ្ជារបស់អតិថិជនដើម្បីជូនដំណឹងអ្នកទទួលថា គណនីរបស់អ្នកទទួលត្រូវបានផ្ទេរទឹកប្រាក់ចូល ឬការផ្ទេរប្រាក់នេះមានប្រសិទ្ធភាពចំពោះគណនីរបស់អ្នកទទួល។

## ១១. អបរិយាប័ន្ននៃការទទួលខុសត្រូវ

១១.១ បន្ថែមទៅនឹង និងដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិនៃខ និងលក្ខខណ្ឌ ធនាគារកម្ពុជាសាធារណៈមិនទទួលខុសត្រូវ ឬរ៉ាប់រងការខូចខាតណាមួយ (មិនថាជាសំណងមិនចំពោះ) ការខាតបង់ ការប៉ះពាល់កិត្តិយស ការចំណាយ ឬការខាតបង់ប្រាក់ចំណេញដែលបានរ៉ាប់រង ឬទទួលរងដោយអតិថិជនដោយសារហេតុផល ឬពាក់ព័ន្ធដូចខាងក្រោម៖

១១.១.១ ការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com របស់អតិថិជន

១១.១.២ សេវាគេហទំព័រ CPBeBank.com មិនអាចចូលប្រើប្រាស់បាន

១១.១.៣ ការចូលប្រើប្រាស់ ការប្រើប្រាស់ ឬភាពអសមត្ថភាពចូលប្រើប្រាស់ ឬប្រើប្រាស់គេហទំព័រនេះ និង/ឬគេហទំព័រផ្សេងដែលភ្ជាប់ទៅនឹងគេហទំព័រនេះ

១១.១.៤ ការខកខាន ការពន្យារពេលបញ្ជូន ភាពរអាក់រអួល បញ្ហា ព័ត៌មានមិនពេញលេញ ឬការខូចខាតគ្រឿងបរិក្ខារ ប្រព័ន្ធ សូហ្វែ ឬម៉ាស៊ីនរបស់ធនាគារកម្ពុជាសាធារណៈ ឬភ្នាក់ងាររបស់ធនាគារ

១១.១.៥ ការវាយប្រហារ ឬការរំខានដោយសារមេរោគកុំព្យូទ័រ ការលោតពុម្ពអក្សរ ឬដោយបុគ្គលណាមួយ

១១.១.៦ ការខកខាន ឬការពន្យារណាមួយដោយសារសេវាកម្មដែលផ្តល់ជូនដោយអ្នកផ្តល់សេវាបណ្តាញអ៊ិនធើណិត

១១.១.៧ ការខកខាន ឬការពន្យារពេលអនុវត្តកាតព្វកិច្ចរបស់ធនាគារកម្ពុជាសាធារណៈដោយសារមូលហេតុ ដែលលើសពីការគ្រប់គ្រងរបស់ធនាគារកម្ពុជាសាធារណៈ មានដូចជាសារាចរណែនាំរបស់រដ្ឋាភិបាល ឬប្រទេសផ្សេងៗ ការឆ្លងរាលដំងឺជាសាកល ឬបុព្វហេតុផ្សេងៗ ដូចជា កូដកម្ម ចំណាត់ការឧស្សាហកម្ម ការរំខានដោយជនស៊ីវិល ទឹកជំនន់ រញ្ជួយដី បាក់ដី ឬប្រធានសក្តិ ឬការមិនដំណើរការប្រព័ន្ធកុំព្យូទ័រ អេឡិចត្រូនិច ទូរគមនាគមន៍ ឬប្រព័ន្ធអេឡិចត្រូនិច មិនដំណើរការ ឬខូចប្រព័ន្ធ ឬភាពរអាក់រអួល ការមិនផ្គត់ផ្គង់ ការខូច ឬការខកខានការផ្គត់ផ្គង់ថាមពលអគ្គិសនី ឬថាមពលក្នុងរយៈពេលណាមួយ

១១.១.៨ ភាពមិនស៊ីគ្នា បញ្ហា ភាពមិនគ្រាប់គ្រាន់នៃមាតិកាគេហទំព័រ ឬគេហទំព័រដែលភ្ជាប់ទៅនឹងសេវាគេហទំព័រ CPBeBank.com

១១.១.៩ ការមិនដំណើរការប្រតិបត្តិការ ឬការខូចម៉ាស៊ីនកុំព្យូទ័រ ប្រព័ន្ធ ឬសូហ្វែដែលប្រើសម្រាប់ចូលប្រើប្រាស់សេវាគេហទំព័រ CPBeBank.com

១១.១.១០ ព័ត៌មានមិនពេញលេញ ឬការពន្យារពេលក្នុងការអនុវត្ត ឬការមិនអនុវត្តកាតព្វកិច្ចរបស់អតិថិជនអនុលោមតាមបទប្បញ្ញត្តិនៃខ និងលក្ខខណ្ឌ

១១.១.១១ ធនាគារកម្ពុជាសាធារណៈអនុវត្តតាមការបញ្ជាដែលបានបញ្ជូន ដោយប្រើប្រាស់អត្តសញ្ញាណសម្គាល់អ្នកប្រើប្រាស់ និងលេខកូដសម្ងាត់

១១.១.១២ ធនាគារកម្ពុជាសាធារណៈអនុវត្តតាមការបញ្ជារបស់បុគ្គលណាម្នាក់ ដែលជាហត្ថលេខីទទួលសិទ្ធិអនុញ្ញាតនៃគណនីរួម និង

១១.១.១៣ ការចូលប្រើប្រាស់គេហទំព័រដែលភ្ជាប់ទៅនឹងសេវាគេហទំព័រ CPBeBank.com។

## ១២. សិទ្ធិថតចម្លង និងស្លាកសញ្ញា

១២.១ លើកលែងតែមានការកំណត់ផ្សេងពីនេះ រាល់សិទ្ធិថតចម្លង ម៉ាកសញ្ញា/ម៉ាកសេវាកម្ម ប៉ាតង់ ឡូហ្គោ និងសិទ្ធិកម្មសិទ្ធិបញ្ញារបស់ធនាគារកម្ពុជាសាធារណៈ ឬអ្វីផ្សេងៗទៀតនៅលើគេហទំព័រនេះ និងមាតិកា និងនៅលើសេវាគេហទំព័រ CPBeBank.com (មានដូចជាព័ត៌មាន ព័ត៌មានលម្អិត ក្រាហ្វិក ទិន្នន័យ ហ្វាល់ អត្ថបទ សំឡេង លំដាប់តៗគ្នា និងការរៀបចំដូចគ្នា) ត្រូវតែជាកម្មសិទ្ធិ និងនៅតែជាកម្មសិទ្ធិរបស់ធនាគារកម្ពុជាសាធារណៈគ្រប់ពេល និងភាគីទីបីដែលពាក់ព័ន្ធ។ គ្មានផ្នែក ឬផ្នែកនៃគេហទំព័រនេះត្រូវបានផលិតឡើងវិញ ថតចម្លង កែតម្រូវ ចែកចាយ ផ្សព្វផ្សាយ បញ្ជូន រក្សាទុក ធ្វើប្រតិបត្តិការ ផ្តល់អាជ្ញាប័ណ្ណ លក់ ឬកែតម្រូវដោយមិនមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់បុគ្គល ដែលទទួលបានសិទ្ធិអនុញ្ញាតរបស់ធនាគារ កម្ពុជាសាធារណៈ ឬភាគីទីបីដែលពាក់ព័ន្ធ។ ការបញ្ចូលតំណភ្ជាប់គេហទំព័រនេះទៅលើ គេហទំព័រផ្សេងទៀត ស៊ុម ឬ "កញ្ចក់" នៃមាតិកាណាមួយនៃគេហទំព័រនេះ ឬគេហទំព័រផ្សេង ឬសូហ្វេត្រូវបានហាមឃាត់ លុះត្រាតែមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីបុគ្គលដែលទទួលបានសិទ្ធិអនុញ្ញាតរបស់ធនាគារកម្ពុជាសាធារណៈ ឬភាគីទីបីដែលពាក់ព័ន្ធ។

១២.២ ធនាគារអាចបង្ហាញ និងប្រើឡូហ្គោភាគីខាងក្រៅក្នុងគោលបំណងផ្សព្វផ្សាយសេវាកម្ម និង/ឬផលិតផលរបស់ធនាគារ។

១២.៣ អតិថិជនយល់ថា សេវាគេហទំព័រ CPBeBank.com ឬគេហទំព័ររបស់ធនាគារមិនត្រូវបានប្រើក្នុងគោលបំណងណាមួយដែលបំពានច្បាប់ រំលោភបំពាន ប្រមាទ អាសគ្រាម ឬគំរាមកំហែង ហើយមិនត្រូវបានប្រើផ្ទុយទៅនឹងច្បាប់ ឬបទដ្ឋានគតិយុត្តិណាមួយឡើយ។

## ១៣. តំណភ្ជាប់

១៣.១ អតិថិជនយល់ថា ធនាគារកម្ពុជាសាធារណៈអាចបញ្ចូល hyperlink ពី ឬទៅកាន់គេហទំព័រដែលជាកម្មសិទ្ធិ ឬធ្វើប្រតិបត្តិការដោយភាគីទីបីដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារកម្ពុជាសាធារណៈ និង/ឬសម្ព័ន្ធធនាគារសាធារណៈ។

១៣.២ តាមរយៈការផ្តល់ hyperlink លើសេវាគេហទំព័រ CPBeBank.com ធនាគារមិនចុះបដិលេខ និងមិនទទួលខុសត្រូវចំពោះគេហទំព័រដែលបានតភ្ជាប់ ហើយបដិសេធចំពោះការទទួលខុសត្រូវចំពោះការអនុវត្តឯកជនភាព ឬមាតិកាគេហទំព័រដែលបានតភ្ជាប់។ អតិថិជនយល់ និងទទួលស្គាល់ភាពចាំបាច់ចំពោះការពិនិត្យខ និងលក្ខខណ្ឌតំណភ្ជាប់ដែលបានគ្រោងទុក គោលនយោបាយ និងបញ្ហាផ្សេងៗដែលឆ្លើយតបទៅនឹងឯកសារនានាដើម្បីស្វែងយល់ពីប្រសិទ្ធភាពមាតិកា ឬសេវាកម្មរបស់ភាគីទីបីមុនពេលប្រើប្រាស់។

១៣.៣ បុគ្គលណាម្នាក់ដែលភ្ជាប់ទៅគេហទំព័រនេះដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីបុគ្គលទទួលសិទ្ធិអនុញ្ញាតរបស់ធនាគារកម្ពុជាសាធារណៈ ត្រូវទទួលខុសត្រូវចំពោះការស្នើសុំទូទាត់ដែលផ្តើមចេញពីតភ្ជាប់ដោយមិនមានការអនុញ្ញាត។

## ១៤. សិទ្ធិកាត់កង

១៤.១ អតិថិជនយល់ព្រមថា ធនាគារកម្ពុជាសាធារណៈអាចជូនដំណឹងជាលាយលក្ខណ៍រក្សានៅពេលណាមួយក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃទៅអតិថិជនដើម្បីស្នើសុំកាត់កងទឹកប្រាក់ដែលជាប់ជំពាក់ធនាគារកម្ពុជាសាធារណៈដោយសារតែ ឬកើតចេញពីប្រតិបត្តិការដែលបានធ្វើឡើងតាមរយៈសេវាគេហទំព័រ CPBeBank.com។ អតិថិជនមិនត្រូវឱ្យធនាគារកម្ពុជាសាធារណៈទទួលខុសត្រូវចំពោះការស្នើសុំទូទាត់ណាមួយ ដែលផ្តើមចេញពីការអនុវត្តសិទ្ធិកាត់កងរបស់ធនាគារ។

## ១៥. ការបញ្ចេញព័ត៌មាន

១៥.១ ដើម្បីផ្តល់ជូនអតិថិជននូវផលិតផលហិរញ្ញវត្ថុ និងសេវាកម្មដ៏សំបូរបែបដែលផ្តល់ជូនដោយធនាគារកម្ពុជាសាធារណៈតាមអ៊ិនធើណិត ភាពចាំបាច់សម្រាប់ព័ត៌មានអំពីអតិថិជនដែលត្រូវផ្សព្វផ្សាយ ឬរកបានតាមអ៊ិនធើណិតទៅក្រុមហ៊ុនបុត្រសម្ព័ន្ធធនាគារកម្ពុជាសាធារណៈ និងទៅភ្នាក់ងារ អ្នកផ្គត់ផ្គង់ អ្នកទិញ និងក្រុមហ៊ុនផ្តល់សេវាកម្មរបស់ធនាគារកម្ពុជាសាធារណៈដែលផ្តល់ការគាំទ្រ និងសេវាកម្មសម្រាប់ផលិតផល និងសេវាកម្មរបស់ធនាគារកម្ពុជាសាធារណៈ។ ព័ត៌មានរបស់អតិថិជននឹងមិនត្រូវបានផ្តល់ទៅភាគីទីបីក្នុងគោលបំណងណាមួយក្រៅពីគោលបំណងខាងលើ ហើយមានតែព័ត៌មាននេះប៉ុណ្ណោះដែលតម្រូវផ្តល់។

១៥.២ ប្រសិនបើអតិថិជនមិនយល់ស្របឱ្យធនាគារកម្ពុជាសាធារណៈបង្ហាញ ឬបញ្ចេញព័ត៌មានដែលផ្តល់ជូនដោយអតិថិជនក្នុងសម្ព័ន្ធធនាគារកម្ពុជាសាធារណៈ និងភ្នាក់ងារ អ្នកផ្គត់ផ្គង់ អ្នកលក់ និងក្រុមហ៊ុនសេវាកម្មរបស់ធនាគារកម្ពុជាសាធារណៈ អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកធនាគារកម្ពុជាសាធារណៈតាមអាសយដ្ឋានដូចខាងក្រោម៖
អគារធនាគារកម្ពុ
លេខ ២៣ វុទ្ធិវិថីក្រមួនស (ផ្លូវ ១១៤)
សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

១៥.៣ អតិថិជនអាចព្រមព្រៀងផ្តល់ព័ត៌មានផ្ទាល់ខ្លួនទៅបុគ្គលដូចមាននៅក្នុងខ និងលក្ខខណ្ឌនេះ និងតាមតម្រូវការច្បាប់។

១៥.៤ ទន្ទឹមពេលដែលធនាគារកម្ពុជាសាធារណៈប្តេជ្ញាយកចិត្តទុកដាក់ និងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធានាថា ព័ត៌មានដែលបានបញ្ជូន និងទទួលមានសុវត្ថិភាព អតិថិជនទទួលស្គាល់ពីហានិភ័យដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់អ៊ិនធើណិត ហើយថា ធនាគារកម្ពុជាសាធារណៈមិនអាចធានាពីសុវត្ថិភាពរបស់ព័ត៌មានដូចបានលើកឡើងខាងលើ ហើយថា មិនអាចចូលប្រើប្រាស់បានដោយភាគីទីបីដែលគ្មានសិទ្ធិអនុញ្ញាត។ អតិថិជនយល់ព្រមមិនឱ្យធនាគារទទួលខុសត្រូវចំពោះការបាត់បង់ ឬខូចខាតដែលផ្តើមចេញពីការបង្ហាញព័ត៌មានដូចបានកំណត់ក្នុងខ និងលក្ខខណ្ឌនេះ។

## ១៦. ការគិតកម្រៃរបស់ធនាគារ

១៦.១ អតិថិជនយល់ព្រម និងធានាអះអាងទូទាត់សងធនាគារកម្ពុជាសាធារណៈនូវរាល់កម្រៃសេវា ឬប្រតិបត្តិការដែលធនាគារកម្ពុជាសាធារណៈ អាចកំណត់ពីពេលមួយទៅពេលមួយពាក់ព័ន្ធទៅនឹងសេវាគេហទំព័រ CPBeBank.com ហើយការគិតកម្រៃសេវាកម្ម ឬប្រតិបត្តិការនេះនឹងត្រូវកាត់កងចេញពីគណនីរបស់អតិថិជននៅពេលមានភាពចាំបាច់។ រាល់កម្រៃសេវា ឬសោហ៊ុយប្រតិបត្តិការដែលត្រូវបង់ត្រូវបញ្ចូលពន្ធនានាដែលត្រូវបង់។

## ១៧. ការបញ្ចប់

១៧.១ ក្នុងករណីមានចំណុចណាមួយផ្ទុយពីនេះ ធនាគារកម្ពុជាសាធារណៈអាចព្យួរ ឬបញ្ចប់សិទ្ធិចូលប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ឬផ្នែកណាមួយចាប់ពីថ្ងៃជូនដំណឹង។

១៧.២ ធនាគារកម្ពុជាសាធារណៈមានសិទ្ធិបញ្ចប់ការចូលប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ក្នុងករណីអតិថិជនបិទគណនីណាមួយនៅធនាគារកម្ពុជាសាធារណៈដែលអាចចូលប្រើប្រាស់តាមរយៈសេវាគេហទំព័រ CPBeBank.com ឬក្នុងករណីការចូលប្រើប្រាស់គណនីរបស់អតិថិជនត្រូវបានរឹតត្បិតដោយធនាគារកម្ពុជាសាធារណៈ ឬភាគីផ្សេងដោយសារហេតុផលណាមួយ។

១៧.៣ អតិថិជនអាចបញ្ចប់ការប្រើប្រាស់ និងការចូលប្រើប្រាស់ របស់ខ្លួនទៅកាន់ គេហទំព័រ CPBeBank.com ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ ជាមុន ទៅធនាគារកម្ពុជាសាធារណៈ។ សេវាគេហទំព័រ CPBeBank.com ដែលផ្តល់ជូនអតិថិជនត្រូវបានលុបចោលក្នុងរយៈពេលប្រាំពីរ (៧) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែលធនាគារបានទទួលសេចក្តីជូនដំណឹងអំពីការបញ្ចប់។ អតិថិជនយល់ព្រមថានឹងមិនប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ចាប់ពីកាលបរិច្ឆេទនៃការជូនដំណឹងរបស់អតិថិជនអំពីការបញ្ចប់ ហើយយល់ព្រមបន្ថែមទៀតថា ធនាគារកម្ពុជាសាធារណៈនឹងមិនមានកាតព្វកិច្ចធ្វើឱ្យការបញ្ជារបស់អតិថិជនប្រសិទ្ធភាពដែលទទួលបាននៅកាលបរិច្ឆេទ បន្ទាប់ពីការទទួលសេចក្តីជូនដំណឹងអំពីការបញ្ចប់។

១៧.៤ ក្នុងករណីគណនីរួម ម្ចាស់គណនីម្នាក់ ឬទាំងអស់យល់ព្រមថា ការបញ្ចប់ការប្រើប្រាស់ សេវាគេហទំព័រ CPBeBank.com អាចត្រូវបានជូនដំណឹងដោយនរណាម្នាក់ក្នុងចំណោមហត្ថលេខីទទួលបានសិទ្ធិអនុញ្ញាតរបស់ម្ចាស់គណនីរួម។

១៧.៥ អតិថិជនទទួលស្គាល់ថា ការបញ្ចប់នឹងមិនប៉ះពាល់ដល់ការទទួលខុសត្រូវ ឬកាតព្វកិច្ចរបស់អតិថិជនពាក់ព័ន្ធទៅនឹងការបញ្ជាដែលបានដំណើរការរួចហើយ និង/ឬធ្វើឱ្យមានប្រសិទ្ធភាពដោយធនាគារកម្ពុជាសាធារណៈជំនួសមុខឱ្យអតិថិជន។

## ១៨. ភស្តុតាង

១៨.១ រាល់កំណត់ត្រាដែលរក្សាទុកដោយធនាគារមិនថាជាទម្រង់អ្វីក៏ដោយ ត្រូវចាត់ទុកជាភស្តុតាងស្ថាពរ និងដាច់ស្រេចក្នុងការដាក់បន្ទុកលើខ្លឹមសារនៃការបញ្ជារបស់អតិថិជន។

១៨.២ អតិថិជនព្រមព្រៀងថា រាល់ការបញ្ជាដែលបានបញ្ជូនដោយឧបករណ៍ ឬមធ្យោបាយផ្សេងរបស់អតិថិជន តាមរយៈទម្រង់អេឡិចត្រូនិចៈ

១៨.២.១ ជាឯកសារលាយលក្ខណ៍អក្សរ ហើយអតិថិជនព្រមព្រៀងមិនតវ៉ា ឬបង្កបញ្ហាលើសុពលភាព ឬភាពអនុវត្តបានរបស់ការបញ្ជាណាមួយដោយឈរលើហេតុផលថា វាមិនមែនជាឯកសារលាយលក្ខណ៍អក្សរ ហើយអតិថិជនលើកលែងសិទ្ធិណាមួយដែលផ្តល់ជូនដោយច្បាប់។

១៨.២.២ គឺជាឯកសារច្បាប់ដើម ហើយអតិថិជនព្រមព្រៀងថាមិនបង្កផលវិបាកចំពោះលទ្ធភាពទទួលយកបានសម្រាប់ការបញ្ជាណាមួយ ដោយឈរលើហេតុផលដែលធ្វើឡើងក្នុងទម្រង់អេឡិចត្រូនិច។

១៨.៣ អតិថិជនទទួលស្គាល់ និងឯកភាពថា កំណត់ត្រារបស់ធនាគារ និងកំណត់ត្រានៃការបញ្ជាណាមួយដែលបានធ្វើឡើង ឬអនុវត្ត ដំណើរការ ឬធ្វើឱ្យមានប្រសិទ្ធភាពតាមរយៈសេវាគេហទំព័រ CPBeBank.com ដោយអតិថិជន ឬបុគ្គលណាម្នាក់ជំនួសមុខឱ្យអតិថិជន ឬកំណត់ត្រានៃប្រតិបត្តិការណាមួយដែលពាក់ព័ន្ធទៅនឹងសេវាគេហទំព័រ CPBeBank.com និងកំណត់ត្រានៃប្រតិបត្តិការដែលបានរក្សាទុក ឬដោយបុគ្គលពាក់ព័ន្ធដែលអនុញ្ញាតដោយធនាគារពាក់ព័ន្ធ ឬជាប់ទាក់ទងទៅនឹងសេវាគេហទំព័រ CPBeBank.com មិនថារក្សាទុកក្នុងទម្រង់អេឡិចត្រូនិច ឬបោះពុម្ព ត្រូវភ្ជាប់កាតព្វកិច្ច និងដាច់ស្រេចចំពោះអតិថិជនគ្រប់គោលបំណងទាំងអស់ ហើយត្រូវចាត់ទុកជាភស្តុតាងដាច់ស្រេចនៃការបញ្ជា និងប្រតិបត្តិការ ព្រមទាំងការទទួលខុសត្រូវរបស់អតិថិជនចំពោះធនាគារ។ អតិថិជនព្រមព្រៀងថារាល់កំណត់ត្រាដែលអាចទទួលយកបានជាភស្តុតាង ហើយថា អតិថិជននឹងមិនបង្កផលវិបាក ឬវិវាទលើលទ្ធភាពទទួលយកការជឿទុកចិត្ត សុក្រឹត្យភាព ឬការពិនិត្យភាពត្រឹមត្រូវនៃមាតិកានៃកំណត់ត្រាដែលកំណត់ត្រានេះត្រូវបញ្ចូល និង/ឬមាននៅក្នុងទម្រង់អេឡិចត្រូនិច ឬផលិតដោយ ឬទិន្នផលនៃប្រព័ន្ធកុំព្យូទ័រ និងអតិថិជនលើសិទ្ធិណាមួយ (ប្រសិនបើមាន) ចំពោះការជំទាស់។

## ១៩. គ្រឿងបរិក្ខារ និងការចូលប្រើប្រាស់បណ្តាញ

១៩.១ អតិថិជនត្រូវ និងជាបន្ទុកចំណាយផ្ទាល់ខ្លួន ទទួលខុសត្រូវចំពោះការទិញ តម្លៃ ការដំឡើង ការថែទាំ ការប្រើប្រាស់ និងជួសជុល (ប្រសិនបើមាន) គ្រឿងបរិក្ខារកុំព្យូទ័រ បរិក្ខារ និងសូហ្វែទូរគមនាគមន៍ ("គ្រឿងបរិក្ខារ") ដែលត្រូវការចាំបាច់ដើម្បីឱ្យអតិថិជនចូលប្រើប្រាស់ អ៊ិនធើណិត និងសេវាគេហទំព័រ CPBeBank.com។ គ្រឿងបរិក្ខារត្រូវស្របទៅតាមលក្ខណបច្ចេកទេសតាមការកំណត់របស់ធនាគារកម្ពុជាសាធារណៈ ប្រសិនបើមាន។

១៩.២ អតិថិជនត្រូវទទួលខុសត្រូវចំពោះកម្រៃទូរគមនាគមន៍ដែលបានកើតឡើង ដោយក្នុងនោះរួមមានកម្រៃជាវ កម្រៃ និងសោហ៊ុយផ្សេងៗដែលកំណត់ដោយអ្នកផ្តល់សេវាបណ្តាញ និងភាគីទីបីផ្សេងទៀត។

## ២០. ករណីកិច្ចរក្សាការសម្ងាត់របស់អតិថិជន

២០.១ អតិថិជនទទួលស្គាល់លក្ខខណ្ឌតម្រូវនៃការរក្សាការសម្ងាត់ និងកាតព្វកិច្ចដែលកំណត់លើធនាគារកម្ពុជាសាធារណៈអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិកម្ពុជាដែលមានវិសាលភាពចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងអះអាងថាមិនធ្វើ ឬបង្កឱ្យធ្វើតាមរយៈទង្វើ ឬព័ត៌មានមិនពេញលេញដែលបណ្តាលឱ្យធនាគារកម្ពុជាសាធារណៈរំលោភបំពានករណីកិច្ចនៃការរក្សាការសម្ងាត់ និងកាតព្វកិច្ចដូចបានលើកឡើងខាងលើ។ កាតព្វកិច្ចចំពោះអតិថិជនដែលមាននៅក្នុងឯកសារនេះត្រូវរួចផុតពីការបញ្ចប់ និង/ឬការផុតកំណត់នៃខ និងលក្ខខណ្ឌនៅក្នុងឯកសារនេះ។

២០.២ ក្នុងករណីអតិថិជនទទួលបានខ្លឹមសារ ឬទិន្នន័យដែលមានព័ត៌មានថាអតិថិជនមិនមែនជាអ្នកទទួលចំគោលដៅ អតិថិជននឹងទទួលបានសេចក្តីជូនដំណឹងថា ការប្រើប្រាស់ ការផ្សព្វផ្សាយ ការចែកចាយ ឬការថតចម្លងខ្លឹមសារ ឬទិន្នន័យណាមួយត្រូវបានហាមឃាត់ និងស្របតាមអភ័យឯកសិទ្ធិតាមផ្លូវច្បាប់។ អតិថិជនយល់ព្រមលុបចោលខ្លឹមសារ ឬទិន្នន័យ និងយល់ព្រមបន្ថែមក្នុងការជូនដំណឹងតាមទូរស័ព្ទមកធនាគារកម្ពុជាសាធារណៈភ្លាមៗ។

## ២១. សំណង

២១.១ អតិថិជនយល់ព្រមសងសំណង និងរក្សាការសងសំណងជូនធនាគារកម្ពុជាសាធារណៈពេញលេញទៅលើ និង/ឬការទទួលខុសត្រូវ ការខាតបង់ ការខូចខាត ទោសទណ្ឌ ចំណាត់ការសាលក្រម ថ្លៃដើម ការចំណាយ ឬប្រាក់ចំណាយលើអ្វីដែលអាចកំណត់ ទូទាត់ ឬអះអាងប្រឆាំងធនាគារកម្ពុជាសាធារណៈពាក់ព័ន្ធទៅនឹងរបាយការណ៍ ការអះអាង ទូរគមនាគមន៍ ទង្វើ និង/ឬព័ត៌មានមិនពេញលេញក្នុងទម្រង់ណាមួយដែលពាក់ព័ន្ធ ឬផ្តើមចេញពីភាពធ្វេសប្រហែស ឬការប្រព្រឹត្តិខុសដោយចេតនា ឬការរំលោភបំពាន ឬព័ត៌មានមិនពេញលេញ ការពន្យារពេល ឬការខកខានអនុវត្តកាតព្វកិច្ចរបស់អតិថិជនដែលស្ថិតក្រោមខ និងលក្ខខណ្ឌដែលមាននៅខ និងលក្ខខណ្ឌនេះ ឬបុព្វហេតុដែលបង្កឡើងដោយអតិថិជន និង/ឬមន្ត្រីណាមួយរបស់ខ្លួនក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនអនុលោមតាមខ និងលក្ខខណ្ឌ។

២១.២ អតិថិជនយល់ព្រមបន្ថែមទៀតថា ធនាគារកម្ពុជាសាធារណៈនឹងមិនទទួលខុសត្រូវចំពោះអតិថិជនចំពោះ និងពាក់ព័ន្ធទៅនឹងការទាមទាររបស់ភាគីទីបី (មានដូចជាអ្នកទូទាត់ដូចមាននៅក្នុងប្រការ ១១.៣ ខាងលើ) ហើយអតិថិជនត្រូវសងសំណង និងការពារមិនឱ្យធនាគារទទួលខុសត្រូវចំពោះការទទួលខុសត្រូវ ការប្តឹងទាមទារ ការខាតបង់ ការខូចខាត ឬការចំណាយ (រួមមានការទទួលខុសត្រូវចំពោះកំហុសស៊ីវិល) ពាក់ព័ន្ធទៅនឹង ឬផ្តើមចេញពីភាគីទីបី ឬអ្នកទូទាត់ដូចបានលើកឡើងខាងលើ និងការរំលោភបំពាន។

២១.៣ អតិថិជនធានាអះអាងសងសំណងជូនធនាគារកម្ពុជាសាធារណៈ ចំពោះការរំលោភបំពានការសម្ងាត់ និងផលវិបាកណាមួយដែលកើតមានឡើង ដែលត្រូវរាប់បញ្ចូលការចូលប្រើប្រាស់ប្រើប្រាស់ព័ត៌មានដោយមិនមានការអនុញ្ញាត ឬដោយខុសច្បាប់ដោយភាគីប្រើប្រាស់ណាមួយ។

២១.៤ ធនាគារកម្ពុជាសាធារណៈមិនទទួលខុសត្រូវចំពោះការបញ្ជាដែលក្លែងបន្លំ ឬមិនមានការអនុញ្ញាត ឬការខាតបង់ណាមួយ (រាប់បញ្ចូលការខាតបង់បន្ទាប់បន្សំ) ការខូចខាត ឬការទទួលខុសត្រូវដែលកើតចេញពីភាពធ្វេសប្រហែស ឬការខកខានដោយចេតនារបស់ធនាគារកម្ពុជាសាធារណៈ។

២១.៥ កាតព្វកិច្ចរបស់អតិថិជនដូចមានក្នុងខ និងលក្ខខណ្ឌនេះត្រូវរួចផុតពីការបញ្ចប់សេវាគេហទំព័រ CPBeBank.com។

## ២២. ការលើកលែង

២២.១ មិនមានការខកខាន ឬការពន្យារលើផ្នែកណាមួយរបស់ធនាគារកម្ពុជាសាធារណៈក្នុងការអនុវត្តសិទ្ធិ អំណាច អភ័យឯកសិទ្ធិ ឬការកែតម្រូវដែលមានក្នុងខ និងលក្ខខណ្ឌនេះត្រូវលើកលែង ឬការព្រមព្រៀងលើការខកខាននេះដែលធ្វើឱ្យប៉ះពាល់ ឬឱនភាពនៃសិទ្ធិ អំណាច អភ័យឯកសិទ្ធិ ឬការកែតម្រូវដែលមាននៅក្នុងខ និងលក្ខខណ្ឌនេះ។

## ២៣. ខបម្រុង

២៣.១ ប្រសិនបើ ខ និងលក្ខខណ្ឌណាមួយលែងមានសុពលភាព ផ្ទុយទៅនឹងច្បាប់ ឬមិនអាចអនុវត្តស្របតាមច្បាប់ណាមួយ នោះសុពលភាព ភាពស្របច្បាប់ និងភាពមិនអាចអនុវត្តបាននៃបទប្បញ្ញត្តិផ្សេងទៀតនៅតែមានប្រសិទ្ធភាព និងមិនបាត់បង់ប្រសិទ្ធភាពឡើយ។

## ២៤. ការផ្លាស់ប្តូរខ និងលក្ខខណ្ឌ

២៤.១ ធនាគារកម្ពុជាសាធារណៈរក្សាសិទ្ធិគ្រប់យ៉ាងក្នុងការកែប្រែ ធ្វើវិសោធនកម្ម ឬបន្ថែមខ និងលក្ខខណ្ឌណាមួយតាមរយៈការជូនដំណឹងក្នុងទម្រង់ណាមួយ ដែលធនាគារចាត់ទុកថាសមស្របពីពេលមួយទៅពេលមួយ។ ក្នុងលក្ខខណ្ឌដូចគ្នានេះ អតិថិជនអាចពិនិត្យខ និងលកខណ្ឌដែលបានកែប្រែ បន្ទាប់ពីចូលប្រើប្រាស់សេវាគេហទំព័រ CPBeBank.com នៅលើគេហទំព័រនេះ និងប្រើប្រាស់សេវានេះ ហើយក្រោយមកបង្កើតការទទួលស្គាល់របស់អតិថិជនចំពោះការកែប្រែ វិសោធនកម្ម ឬការបន្ថែម។

## ២៥. ការភ្ជាប់កាតព្វកិច្ចសន្តិជន

២៥.១ ខ និងលក្ខខណ្ឌនៅក្នុងឯកសារនេះត្រូវភ្ជាប់កាតព្វកិច្ចលើអ្នកតំណាងផ្ទាល់ និងសន្តិជនពេញសិទ្ធិរបស់អតិថិជន និងសន្តិជនពេញសិទ្ធិ អ្នកប្រគល់សិទ្ធិរបស់ធនាគារកម្ពុជាសាធារណៈ ឬរបស់ក្រុមហ៊ុន ដែលតាមរយៈនោះអាជីវកម្មរបស់ធនាគារកម្ពុជាសាធារណៈអាចធ្វើប្រតិបត្តិការបាននៅពេលនោះ ហើយអតិថិជនមិនមានសិទ្ធិប្រគល់សិទ្ធិ ឬកាតព្វកិច្ចរបស់ខ្លួនស្របទៅតាមខ និងលក្ខខណ្ឌនេះបានទេ លុះត្រាទទួលបានការព្រមព្រៀងជាលាយលក្ខណ៍អក្សរជាមុនពីធនាគារកម្ពុជាសាធារណៈ។

## ២៦. ការក្លែងបន្លំ/ការបញ្ជាដែលមានសិទ្ធិអនុញ្ញាត/ការរំលោភបំពានសុវត្ថិភាព

២៦.១ អតិថិជនទទួលស្គាល់ថា ធនាគារនឹងមិនទទួលខុសត្រូវចំពោះការបញ្ជាដែលមានការក្លែងបន្លំ ឬមិនមានការអនុញ្ញាត ឬការខាតបង់ណាមួយ (រាប់បញ្ចូលទាំងការខាតបង់បន្ទាប់បន្សំ) ការខូចខាត ឬការទទួលខុសត្រូវដែលទទួលរងបញ្ហាប្រឈម និង/ឬរ៉ាប់រងដោយអតិថិជន ក្នុងករណី៖

- អតិថិជនធ្វើសកម្មភាពដោយក្លែងបន្លំ និង/ឬ
- អតិថិជនមិនបានអនុវត្តកាតព្វកិច្ចដូចខាងក្រោម៖
  I. ការពារព័ត៌មានធ្វើប្រតិបត្តិការធនាគារផ្ទាល់ខ្លួនរបស់អតិថជន ដូចជាលេខសម្គាល់អ្នកប្រើប្រាស់ លេខកូដសម្ងាត់ និងកុំព្យូទ័រ តាមរយៈការបង្ហាញព័ត៌មានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទៅភាគីទីបី
  II. ចាត់វិធានការបង្ការប្រកបដោយការទទួលខុសត្រូវដើម្បីធ្វើបច្ចុប្បន្នកម្ម និងការពារឧបករណ៍របស់អតិថិជនដើម្បីធានាថា ឧបករណ៍នេះគ្មានការចូលលួចទិន្នន័យ/វីរុស។
  III. ចាត់វិធានការបង្ការប្រកបដោយការទទួលខុសត្រូវដើម្បីធានាថា អតិថិជនផ្លាស់ប្តូរលេខកូដសម្ងាត់ ពិនិត្យព័ត៌មានធ្វើប្រតិបត្តិការធនាគារ និងសមតុល្យរបស់ខ្លួនប្រចាំគ្រា ហើយរក្សាទុកព័ត៌មានធ្វើប្រតិបត្តិការធនាគារ និងសុវត្ថិភាពឧបករណ៍ និងឧបករណ៍ប្រកបដោយសុវត្ថិភាពគ្រប់ពេល។
  IV. រាយការណ៍អំពីការរំលោភបំពាន ឬការបន្ធូរបន្ថយសុវត្ថិភាពដែលមានភាពសង្ស័យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន (ក្នុងរយៈពេល ២៤ ម៉ោង) ដោយមិនគិតពីទីតាំងរបស់អតិថិជន បន្ទាប់ពីបានដឹងអំពីការរំលោភបំពាន ឬខាតបង់ ទាំងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរទៅមន្ត្រីទទួលបន្ទុកផ្នែកអតិថិជនរបស់ធនាគារ ឬសាខាណាមួយរបស់ធនាគារ។
  V. ផ្តល់ជូនធនាគារនូវពាក្យបណ្តឹងផ្លូវការទៅប៉ូលីសឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីរាយការណ៍អំពីការរំលោភបំពានសុវត្ថិភាពធនាគារ និង/ឬ
  VI. ផ្តល់ជូនធនាគារនូវព័ត៌មាន ទាំងតាមផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធទៅនឹងប្រតិបត្តិការមានវិវាទ៖ មានដូចជាឈ្មោះអតិថិជន គណនីដែលមានបញ្ហា កាលបរិច្ឆេទ និងមូលហេតុអ្វីបានជាអតិថិជនជឿជាក់ថាជាប្រតិបត្តិការមានវិវាទ។

២៦.២ ធនាគារត្រូវធ្វើការជាមួយអាជ្ញាធរពាក់ព័ន្ធ និងរក្សាសិទ្ធិចាត់ចំណាត់ការតាមផ្លូវច្បាប់លើអតិថិជនដែលពន្យារពេល រារាំង និង/ឬលាក់បាំងព័ត៌មានសំខាន់ពីធនាគារ ផ្សព្វផ្សាយការប្តឹងទាមទារមិនពិតលើប្រព័ន្ធផ្សព្វផ្សាយប្រពៃណី ឬសង្គម និង/ឬដាក់ពាក្យបណ្តឹងក្លែងក្លាយពាក់ព័ន្ធទៅនឹងប្រតិបត្តិការណាមួយដែលបានធ្វើឡើង ឬធ្វើជំនួសតាមរយៈសេវាគេហទំព័រ CPBeBank.com។

## ២៧. គោលនយោបាយប្រឆាំងការស៊ីសំណូក និងប្រឆាំងអំពើពុករលួយ

២៧.១ ធនាគារបានអនុវត្តគោលនយោបាយប្រឆាំងការស៊ីសំណូក និងប្រឆាំងអំពើរពុករលួយដែលអនុវត្ត "វិធីសាស្ត្រមិនលើកលែង" ចំពោះទម្រង់នៃការស៊ីសំណូក និងពុករលួយក្នុងការធ្វើអាជីវកម្ម។ ធនាគាររក្សាសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះ ក្នុងករណីអតិថិជន ឬមន្ត្រី ឬភ្នាក់ងារណាមួយរបស់ខ្លួនមានជាប់ពាក់ព័ន្ធទៅនឹងអំពីស៊ីសំណូក ឬអំពើពុករលួយ។

## ២៨. សេចក្តីជូនដំណឹង

អតិថិជនយល់ព្រមតាមរាល់សេចក្តីជូនដំណឹង និងការប្រាស្រ័យទាក់ទងផ្សេងៗដែលពាក់ព័ន្ធទៅនឹងសេវាគេហទំព័រ CPBeBank.com ឬតម្រូវស្របតាមខ និងលក្ខខណ្ឌ ឬអាចត្រូវបានផ្តល់តាមរយៈធនាគារកម្ពុជាសាធារណៈក្នុងទម្រង់ណាមួយដូចខាងក្រោម៖

២៨.១ តាមរយៈការផ្ញើតាមប្រៃសណីយ៍ទៅអាសយដ្ឋានអ៊ីម៉ែល ដែលបានដឹងចុងក្រោយរបស់អតិថិជននៅក្នុងកំណត់ត្រារបស់ធនាគារកម្ពុជាសាធារណៈ ហើយការជូនដំណឹងត្រូវចាត់ទុកថាបានទទួលក្នុងរយៈពេលពីរ (២) ថ្ងៃបន្ទាប់ពីបានផ្ញើរួច។

២៨.២ តាមរយៈសារអេឡិចត្រូនិចទៅអាសយដ្ឋានអ៊ីម៉ែល ដែលបានដឹងចុងក្រោយរបស់អតិថិជននៅក្នុងកំណត់ត្រារបស់ធនាគារកម្ពុជាសាធារណៈ ហើយការជូនដំណឹងនេះត្រូវចាត់ទុកថាបានទទួលក្នុងរយៈពេលម្ភៃបួន (២៤) ម៉ោងបន្ទាប់ពីបានផ្ញើរួច។

២៨.៣ តាមរយៈការបិទផ្សាយនៅទីតាំងអាជីវកម្មរបស់ធនាគារកម្ពុជាសាធារណៈ ហើយសេចក្តីជូនដំណឹងនេះត្រូវមានប្រសិទ្ធភាពបន្ទាប់ពីបិទផ្សាយ។

២៨.៤ តាមរយៈការផ្សាយពាណិជ្ជកម្មតាមទំព័រកាសែត ហើយការជូនដំណឹងនេះត្រូវមានប្រសិទ្ធភាពនៅថ្ងៃចេញផ្សាយពាណិជ្ជកម្មលើទំព័រកាសែត។

២៨.៥ តាមរយៈការដាក់បញ្ចូលសេចក្តីជូនដំណឹង ក្នុងរបាយការណ៍ គណនី ធនាគារកម្ពុជាសាធារណៈ ជូនអតិថិជន ហើយសេចក្តីជូនដំណឹងនេះ ត្រូវមានប្រសិទ្ធភាព រយៈពេលពីរ (២) ថ្ងៃពីកាលបរិច្ឆេទផ្សាយសេចក្តីជូនដំណឹងដែលមានភ្ជាប់ក្នុងរបាយការណ៍គណនីជូនអតិថិជន។

២៨.៦ ផ្សព្វផ្សាយសារលើគេហទំព័រនេះ។

២៨.៧ ប្រសិនបើបានជូនដំណឹងទៅអតិថិជនក្នុងទម្រង់ណាមួយដែលធនាគារយល់ថាសមស្រប។

២៨.៨ រាល់សេចក្តីជូនដំណឹងមកធនាគារកម្ពុជាសាធារណៈ ដែលពាក់ព័ន្ធទៅនឹងសេវា គេហទំព័រ CPBeBank.com និងខ និងលក្ខខណ្ឌត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ចុះហត្ថលេខាដោយអតិថិជន និងផ្ញើមកធនាគារកម្ពុជាសាធារណៈទៅតាមអាសយដ្ឋានដូចខាងក្រោម ឬប្រគល់ ឬបញ្ជូន ឬតាមមធ្យោបាយផ្សេងដែលធនាគារកម្ពុជាសាធារណៈជូនដំណឹងមកអតិថិជនពីពេលមួយទៅពេលមួយៈ

អគារធនាគារកម្ពុ
លេខ ២៣ វុក្ខវិថីក្រមួនស (ផ្លូវ ១១៤)
សង្កាត់ផ្សារថ្មី ២ ខណ្ឌដូនពេញ
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ២៩. ច្បាប់ និងយុត្តាធិការ

២៩.១ ការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com នៅលើគេហទំព័រនេះ និងខ និងលក្ខខណ្ឌត្រូវបានគ្រប់គ្រង និងបកស្រាយស្របតាមច្បាប់ប្រទេសកម្ពុជា ហើយគូភាគីត្រូវបញ្ជូនទៅប្រព័ន្ធតុលាការកម្ពុជា ក្នុងករណី សេវាគេហទំព័រ CPBeBank.com នៅលើគេហទំព័រនេះអាចត្រូវបានចូលប្រើបាស់តាមយុត្តាធិការផ្សេង និងត្រូវបានរឹតត្បិតនៅកម្ពុជា។

២៩.២ ការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ក្រៅប្រទេសកម្ពុជាត្រូវស្របតាបច្បាប់ស្តីពីអត្រាប្តូរប្រាក់បរទេស (ថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៧) និងបទប្បញ្ញត្តិគ្រប់គ្រងការប្តូរប្រាក់របស់ធនាគារកណ្តាលម៉ាឡេស៊ី លក្ខខណ្ឌតម្រូវសម្រាប់ត្រួតពិនិត្យសារពើពន្ធ ឬការប្តូរប្រាក់ ឬបទប្បញ្ញត្តិដែលប្រតិបត្តិការនៅក្នុងប្រទេសដែលប្រតិបត្តិការត្រូវបានឱ្យមានប្រសិទ្ធភាព ឬស្នើសុំ។

២៩.៣ ចំនួនទឹកប្រាក់ប្រតិបត្តិការអប្បរមា និងគោលបំណងដែលត្រូវធ្វើឱ្យមានប្រសិទ្ធភាពអាចត្រូវបានកំណត់ដោយធនាគារជាតិនៃកម្ពុជា និងច្បាប់ ព្រមទាំងបទប្បញ្ញត្តិក្នុងប្រទេសដែលប្រតិបត្តិការត្រូវបានឱ្យកើតមាន ឬស្នើសុំ។

២៩.៤ អតិថិជនយល់ព្រមថា អតិថិជនត្រូវទទួលខុសត្រូវតែម្នាក់គត់ចំពោះការអនុវត្តតាមច្បាប់ដែលមានវិសាលភាពចំពោះអតិថិជនក្នុងយុត្តាធិការរបស់អតិថិជន ពាក់ព័ន្ធទៅនឹងការប្រើប្រាស់សេវាគេហទំព័រ CPBeBank.com ។

**TERMS AND CONDITIONS GOVERNING**
**CAMBODIA PUBLIC BANK INTERNET BANKING (CPBeBank.com)**

**NOTICE**:

THIS WEBSITE ALLOWS COMMUNICATION AND INTERACTION BETWEEN CAMBODIAN PUBLIC BANK PLC AND THE CUSTOMER.

BEFORE ACCESSING THIS WEBSITE AND/OR THE USE OF ALL OR ANY OF ITS PAGES, THE CUSTOMER MUST READ, UNDERSTAND AND AGREE TO BE BOUND BY THE TERMS AND CONDITIONS HEREIN AS WELL AS ANY OTHER TERMS WHICH THE BANK MAY PRESCRIBE. IF THE CUSTOMER DOES NOT AGREE TO ACCEPT ANY OF THE TERMS AND CONDITIONS, THE CUSTOMER IS ADVISED TO IMMEDIATELY DISCONTINUE ACCESS TO THIS WEBSITE AND/OR UTILISATION OF ANY PART THEREOF.

THE CUSTOMER IS TO NOTE THAT THE CUSTOMER'S ACCESS OR USE OF THIS WEBSITE SHALL BE AT THE CUSTOMER'S OWN RISK AND INITIATIVE, AND THE CUSTOMER SHALL BE RESPONSIBLE FOR COMPLIANCE OF ALL APPLICABLE LAWS.

## 1. GENERAL

1.1 The information, materials, contents or advice contained in this website do not constitute an invitation to treat or offer to enter into a legally binding contract with Cambodian Public Bank Plc and is provided for general information only.

1.2 The Customer is advised to seek independent legal, financial or other advice as the Customer deems necessary at all times before making any decision based on any information, materials or any content herein.

1.3 The information, materials, contents and functions provided in this website may be changed from time to time without notice at Cambodian Public Bank Plc's absolute discretion.

1.4 This service is only available to Cambodian Public Bank Plc's customers with USD and KHR accounts.

## 2. DEFINITIONS AND CONSTRUCTION

2.1 In these Terms and Conditions, the following words and expressions shall have the following meaning:

1. "Account" means one or more of the Customer's savings account, current account, credit card, loan, fixed deposit or any other accounts with Cambodian Public Bank Plc which may be accessed through the CPBeBank.com Services as determined by Cambodian Public Bank Plc.

2. "Agent" means any third party offering products, services, contents and information on this website.

3. "Agreement" means this agreement between the Customer and Cambodian Public Bank Plc. for the CPBeBank.com Services, all supplements, amendments and variations thereto.

4. "Authorised Person" means the Customer himself who has applied for the CPBeBank.com Services

5. "Bank" means Cambodian Public Bank Plc, a company incorporated in Cambodia having its registered office at Campu Bank Building No. 23, Kramuon Sar Avenue (Street No. 114), Sangkat Phsar Thmey 2, Khan Daun Penh, Phnom Penh, Cambodia as the case may be, and its respective successors in title and assigns and where applicable any of them.

6. "Banking Services" means products and services of Cambodian Public Bank Plc and its Agents as are made available to you on this website.

7. "Bill" means the bill, invoice, notice, renewal notice, form and/or payment demand received by the Customer from a Payee Corporation and which has to be paid within the time frame stipulated in the Payee Corporation's bill, invoice, notice, renewal notice, from and/or payment demand.

8. "Business Hours" means 24 hours daily including holidays.

9. "Customer" means the individual person or persons or the corporate entity in whose name (s) the Account(s) is/are maintained with Cambodian Public Bank Plc and to whom Cambodian Public Bank Plc has agreed to provide the CPBeBank.com Services and where applicable, the Customer's successors in title or legal representatives.

10. Eligible Accounts" means:

   i. In the case of individual Customers, the individual accounts in the Customer's sole name or to joint accounts which the Customer maintains with another person/s and where the mandate for the operation of that joint account is "either one to sign"; or

ii. In the case of a Corporate Customer, the accounts that the Appointed Person is authorised by the Corporate Customer to access and use the CPBeBank.com Services for and on behalf of the said Corporate Customer;

11. "Instruction" means instructions given by the Customer in respect of the Customer's Account(s) via the CPBeBank.com Services.

12. "Internet" means a computer network consisting of a worldwide network of computer networks that use the TCP/IP network protocols to facilitate data transmission and exchange.

13. "Network Service Provider" means any Internet Service Provider ("ISP") or any commercial online service provider or a licensed telecommunications services provider approved by the Bank providing connection to the Internet or providing the Customer with telecommunications and connectivity services necessary for the provisions of any application in addition to its own proprietary network.

14. "PAC" means the CPBe Authentication Code used to confirm and authorise the internet banking transaction effected by the Customer. The PAC will be sent via Short Message System ("SMS") Service by the telecommunications company to the Customer's handphone number registered in the Bank's records.

15. "Password" means a unique string of characters issued by the Cambodian Public Bank Plc for the Customer's first time login to the CPBeBank.com Services and thereafter, chosen by the Customer and known only to the Customer and the CPB computer system, which must be keyed in by the Customer on the Customer's computer terminal in order to authenticate the Customer's User ID and grants the Customer access to the CPBeBank.com Services.
16. "Payee Corporation" means those corporations or bodies approved by the Bank and whose names are displayed on the CPBeBank.com Services bill payment screen.

17. "CPBeBank.com Services" means the Online Internet Banking Service which the Customer may access through the use of a personal computer terminal, modem and/or any other telecommunication device, over the Internet, upon the correct input of the Customer's User ID and Password.

18. "CPB" means Cambodian Public Bank Plc.

19. "Device" means a Computer Terminal or handphone that can be used to connect to the internet.

20. "US Dollar" or "USD" means the lawful currency in the Kingdom of Cambodia to be used for CPBeBank.com Services.

21. "Khmer Riel" or "KHR" means the lawful currency in the Kingdom of Cambodia to be used for CPBeBank.com Services.

22. "Terms and Conditions" means these Terms and Conditions governing the use of the CPBeBank.com Services.

23. "User ID" means the identification access code issued by CPB for the Customer's first time login to the CPBeBank.com Services and thereafter, chosen by the Customer which must be keyed in by the Customer in order for the CPBeBank.com Services system to associate the User ID with the Customer's user profile and account.

24. "Website" means CPBeBank.com or any other address as shall be determined and notified by CPB from time to time.

2.2 Words importing the singular shall include the plural and vice versa.

2.3 Words importing the masculine gender shall include the feminine and neuter gender and vice versa.

2.4 Any banking term not specifically defined or described herein shall be construed in accordance with the general practice of banks and financial institutions in Cambodia. Any terms relating to computer technology not specifically defined or described herein shall be construed in accordance with the general practice and the information technology industry in Cambodia.

2.5 In the event of any conflict in the interpretation of this Terms and Conditions in any language the English version shall prevail.

2.6 Where there are 2 or more persons or parties comprised in the expression "the Customer", the agreements, covenants, stipulations, undertakings, terms and conditions expressed to be made by and on the part of the Customer herein shall be treated and understood as made by or binding upon such persons or parties jointly and severally.

## 3. THE AGREEMENT

3.1 The Terms and Conditions herein and all supplements, amendments and variations thereto shall collectively constitute the agreement between the Customer and CPB ("the Agreement"), and shall apply to the CPBeBank.com Services.

3.2 The Terms and Conditions operate in conjunction with the respective Terms and Conditions and rules and regulations applicable to the Account(s) which the Customer represents that he/she has read, understood and agreed to be bound by without qualification or limitation by use of this website or any of its pages.

3.3 In the event of any conflict or inconsistency between the Terms and Conditions herein and the Terms and Conditions and rules and regulations governing the relevant Account(s), the latter shall prevail for purposes of interpretation and enforcement to the extent of such conflict or inconsistency.

3.4 In addition to the above, these Terms and Conditions operate in conjunction with the respective Terms and Conditions and rules and regulations applicable to PB engage KH Terms and Conditions.

3.5 In the event of any conflict or inconsistency between the Terms and Conditions herein and the Terms and Conditions and rules and regulations governing the relevant Account(s), the latter shall prevail for purposes of interpretation and enforcement to the extent of such conflict or inconsistency.

3.6 The rights to this Agreement may be transferred in part or in full to any company affiliated to CPB. The Customer's rights or obligation under this Agreement may not be transferred to other entity or person.

3.7 Use by the Customer of the CPBeBank.com Services at any time, shall indicate to CPB the Customer's acceptance and agreement to be bound by these Terms and Conditions.

3.8 In the event of any conflict in the interpretation of this Terms and Conditions, the English version shall prevail.

## 4. PURPOSE OF THE CPBeBank.com Services

4.1 The CPBeBank.com Services is provided to the Customer as a mechanism which will enable access to the financial services offered by the CPB.

4.2 The financial services available through the CPBeBank.com Services are provided by the CPB and may include products offered by its subsidiaries. CPB may exclude any financial services on the CPBeBank.com Services at its sole discretion.

